# សាលារៀន ម៊ីដល់ស៊ិក អាខាឌីម៊ី ឆាទើ ប្រចាំក្រុងឡូវែល
# Lowell Middlesex Academy Charter School

## សៀវភៅណែនាំមាតាបិតានិងសិស្ស
## Parent and Student Handbook
## ស្តីពី of
## ច្បាប់វិន័យនិងបទបញ្ញត្តិទាំងឡាយ
## Policies and Regulations

---

Revised 11/30/10

# ចក្ខុវិស័យ
# MISSION STATEMENT

*ចក្ខុវិស័យ ឬការប្រកាសអះអាងជាផ្លូវការនៃវត្ថុបំណងរបស់សាលា* មុីដល់សុិក អាខាឌីមុី ឆាទើ ប្រចាំក្រុងឡូវែល *(អក្សរកាត់ហៅថា* អុិលអុឹមអេសុីអេះ ឬអុិលម៉ាក់) *គឺដើម្បីបណ្តុះបណ្តាលសិស្សានុសិស្សខ្លួនឲ្យអាចទទួលជោគជ័យនូវក្នុងការសិក្សារៀនសូត្រ, ការប្រាស្រ័យទាក់ទងខាងផ្នែកសង្គម និងការប្រកបជីវភាពរស់នៅរបស់ខ្លួនអោយបានប្រសើរផងដែរ ។ សាលារៀនសហគមន៍ដែលប្រកបទៅដោយបរិយាកាសដែលផ្តល់នូវការគាំទ្រនេះ នឹងជួយចង្អុលបង្ហាញគំនិត, ជួយលើកទឹកចិត្ត ហើយនិងជួយបង្កើតនូវការចូលចិត្ត និងសមត្ថភាពផ្សេងៗ ទទ្ទឹមនឹងការទទួលស្គាល់និងការគោរពនូវអត្តសញ្ញាណនិងវប្បធម៌របស់សិស្សម្នាក់ៗ ។*

## សេចក្តីសង្ឃឹមទាំងឡាយរបស់សិស្ស

*បន្ទាប់ពីបានបញ្ចប់ការសិក្សាពីសាលាអុិលម៉ាក់ សិស្សទាំងអស់នឹងអាចមានលទ្ធភាពះ*

1) *អានបានយ៉ាងល្អត្រឹមត្រូវ និងដោយវិធីវិភាគល្អ*
2) *ប្រាស្រ័យទាក់ទងបានល្អទាំងការសរសេរនិងដោយមាត់ទទេទៅកាន់អតិថិជនទាំងឡាយ*
3) *ដោះស្រាយបញ្ហាបានល្អប្រសើរនៅក្នុងស្ថានភាពផ្សេងៗ*
4) *ប្រើប្រាស់បច្ចេកទេសជាឧបករណ៍ ដើម្បីប្រមូល, វិភាគ ហើយនិងបង្ហាញនូវពត៌មានផ្សេងៗ*
5) *បង្ហាញនូវការយល់ដឹងយ៉ាងច្បាស់លាស់នៃសិទ្ធិ ហើយនិងពីភារកិច្ចទាំងឡាយនៃសមាជិកសហគមន៍ម្នាក់ៗ*
6) *បង្ហាញនូវការយល់ដឹង ហើយនិងពីចំណេះនៃវិជ្ជាជីវៈណាមួយ ឬពីជម្រើសការសិក្សាអ្វីមួយ ដើម្បីនឹងបង្កើតនូវគម្រោងការអ្វីមួយសំរាប់អនាគត*

សាលារៀន អុិលម៉ាក់ (LMACS) គឺប្តេជ្ញាចិត្តនឹងធ្វើឲ្យកម្មវិធីសិក្សា ហើយនិងកន្លែងរៀនសូត្រទាំងឡាយរបស់ខ្លួនមានការផ្តល់ជូនដ៏ល្អត្រឹមត្រូវដល់សិស្សគ្រប់ៗគ្នា ។ សាលាអុិលម៉ាក មិនរើសអើងឬប្រកាន់ទៅលើអ្វីៗ ព្រោះអាយុ, ភេទ, ពូជសាសន៍, ពណ៌សម្បុរ, ប្រភពដើមកំណើត, ចំណូលចិត្តផ្នែកភេទ, ពិការភាព, សេចក្តីត្រូវការពិសេស, ភាពស្ទាត់ជំនាញខាងភាសាអង់គ្លេស ឬភាសាបរទេសផ្សេងទៀត ឬក៏ពីស្នាដៃខាងផ្នែកសិក្សាអ្វីផ្សេងៗ ដែលមានពីពេលមុននោះឡើយ ។

# ការបង្រៀន និងការសិក្សានៅសាលារៀន អ៊ិលម៉ាក់

# TEACHING AND LEARNING AT LMACS

## សាលារៀន អ៊ិលម៉ាក់ (LMACS)

- *បានវិវឌ្ឍន៍ចាប់ផ្តើមពីកម្មវិធីជួយសិស្សដែលបានចាកចេញពីសាលាឲ្យចូលរៀនឡើងវិញ ដោយផ្តោតទៅលើការបញ្ចប់នៃពិន្ទុដែលចាំបាច់ រហូតដល់ទៅការសិក្សាកំរិតវិទ្យាល័យដ៏ទូលំទូលាយ ដែលផ្តោតទៅលើការផ្តល់នូវមុខវិជ្ជាជីវៈទូទៅ, កម្មវិធីបង្រៀនដែលមានគុណភាពល្អកំរិតខ្ពស់ សំរាប់សិស្សានុសិស្សដែលប្រឈមមុខនឹងបញ្ហាលំបាកផ្សេងៗ ។*

- *ទទួលបំរើសិស្សដែលមានភាពលំបាកផ្សេងៗ ចំនួន* 120 *នាក់ ។ វាគឺជាសាលាហ៊ឹកហ៊ឺនកំរិតថ្នាក់វិទ្យាល័យសំរាប់សិស្សទាំងឡាយណាដែលធ្លាប់បានចាកចេញពីសាលារៀននានា ។ សាលា អ៊ិលម៉ាក់ ជួយផ្តល់នូវការសិក្សាដ៏ពិសេសតាមរយៈគំរូគមួយ ឈ្មោះថា កម្មវិធីបង្រៀនបន្ថែមបញ្ចូលជាមួយគ្នា ។*

- *កម្មវិធីបង្រៀន គឺស្ថាបនាឡើងនៅជុំវិញចំណុះសំខាន់ៗនៃការសិក្សាមុខវិជ្ជាទូទៅ ដែលជួយផ្តល់បន្ថែមទៀត ដោយថ្នាក់រៀនផ្សេងៗ តាមកម្មវិធីបង្រៀនលក្ខណៈសិក្សាចិត្តសាស្ត្រ និងជាក្រុមៗ, ដែលមានសមាសភាគពីសាលាទៅនឹងការងារ, ដែលផ្តល់នូវការទូន្មានជារៀងរាល់ថ្ងៃ ហើយនិងអាចចុះឈ្មោះយកថ្នាក់រៀនផ្សេងៗនៅមហាវិទ្យាល័យ អ៊ិមស៊ីស៊ី ដែលត្រូវបានគេចាក់ទុកនៅក្រោមកម្មវិធីចុះឈ្មោះសិក្សាជាទ្វេគុណ* (Dual Enrollment Program) *។ កម្មវិធីសិក្សានៅសាលា អ៊ិលម៉ាក់ គឺផ្តោតទៅលើទំហំថ្នាក់តូចល្មមគួរសម ហើយនិងដែលឆ្ពោះទៅលើបេសកម្មសិក្សាវប្បធម៌របស់ខ្លួន ។*

- *កាលបរិច្ឆេទសិក្សាគឺមានលក្ខណៈខុសប្លែកគ្នាពីសាលាវិទ្យាល័យធម្មតា ។ ថ្នាក់និមួយៗ គឺមានចំនួន* 55 *នាទី ។ ម៉ោងសិក្សា គឺចាប់ពីម៉ោង* 9:00 *ព្រឹក ដល់ម៉ោង* 3:30 *ល្ងាច ។ ថ្នាក់រៀនទាំងឡាយ គឺជួបជារៀងរាល់ថ្ងៃ ពីថ្ងៃចន្ទ រហូតដល់ថ្ងៃព្រហស្បតិ៍ ។ មានការបង្រៀនបន្ថែមផ្ទាល់ គឺគ្រូម្នាក់នឹងសិស្សម្នាក់ ហើយនិងពេលវាលាជំនួយបន្ថែមផ្សេងទៀត គឺចាប់ពីម៉ោង* 9:00*ព្រឹក ដល់ម៉ោង* 12:00 *ថ្ងៃត្រង់ ជារៀងរាល់ថ្ងៃសុក្រផងដែរ ។*

- *ថ្នាក់រៀងទាំងឡាយ គឺតម្រូវឲ្យបានពិន្ទុយ៉ាងតិចណាស់* 70% (C-) *ដើម្បីនឹងអាចរៀនចប់ថ្នាក់បាន ។ សិស្សនិងក្រុមគ្រួសារ ឬអ្នកអាណាព្យាបាលគ្រប់ៗគ្នា នឹងទទួលរបាយការណ៍សិក្សាផ្សេងៗក្នុងចន្លោះត្រីមាស និងនៅចុងបញ្ចប់ត្រីមាសនិមួយៗ ហើយនិងរបាយការណ៍នៃកម្មវិធីសិក្សាពិសេសផងដែរ, បើសិនជាមានការសិក្សាផ្នែកនេះ ។*

- *សិស្សទាំងអស់គ្នា គឺត្រូវជួបជុំគ្នាក្នុងលក្ខណៈផ្តល់ដំបូន្មានជាក្រុមៗ ជារៀងរាល់ថ្ងៃ ។ ទីប្រឹក្សាសាលាទាំងឡាយនឹងជួយធ្វើកាលបរិច្ឆេទឲ្យសិស្សម្នាក់ៗ, ជួយពិនិត្យមើលការរីកចំរើននៃសិស្ស ហើយនិងជួយទាក់ទងទៅតាមផ្ទះសិស្សផងដែរ។ ទីប្រឹក្សាសាលានឹងផ្តល់ពត៌មានផ្សេងៗដល់ក្រុមគ្រួសារ និងអ្នកអាណាព្យាបាលជារៀងរាល់ពីរសប្តាហ៍ម្តង ដើម្បីផ្តល់នូវរបាយការណ៍រីកចំរើនផ្សេងៗ របស់សិស្ស ។*

- *ជួបប្រជុំពិភាគសិក្សាគ្នាជារៀងរាល់ខែ ។ ការប្រជុំម្តងៗ គឺផ្តោតទៅលើតំលៃណាមួយនៃតំលៃអកិសមាចារទាំងដប់របស់សាលា អ៊ិលម៉ាក់ ។ កម្មវិធីវប្បធម៌ផ្សេងៗ គឺត្រូវបានគេរាប់បញ្ចូលទៅក្នុងការជួបជុំសិក្សាទាំងឡាយ ។ សិស្សគ្រប់ៗគ្នានឹងបានចូលទៅទស្សនាកំសាន្តនូវរឿងល្ខោននានា នៅរោងល្ខោន ម៉ារីម៉ាក, ទៅទស្សនាសារមន្ទីរ, និងទៅមើលកុនឯកសារផ្សេងៗ ទៀត ។ ការជួបជុំទាំងឡាយនេះ ក៏មានរូមបញ្ចូលភ្ញៀវដែលធ្វើសន្ទរកថាផ្សេងៗផងដែរ ។*

- *គឺប្តេជ្ញាចិត្តដើម្បីជួយសិស្សម្នាក់ៗ ឲ្យអាចទទួលបានជោគជ័យ ។*

# **ទិដ្ឋាសិក្សានៃសាលា អ៊ិលម៉ាក់**
## (**LMACS COURSE OF STUDY)**

*កម្មវិធីសិក្សានៃសាលាអ៊ិលម៉ាក់ គឺត្រូវបានគេហៅថា "ហ្វេស្សិះ* (**Phases-**ដំណាក់កាលអនុវត្តន៍)៖ មាគ៌ាឆ្ពោះទៅកាន់សមិទ្ធិផល" *។ រចនាសព័ន្ធដែលមានទ្រង់ទ្រាយអភិវឌ្ឍន៍និមយនេះ គឺត្រូវបានគេយកមកអនុវត្ត ដើម្បីដោះស្រាយបញ្ហាខ្វះខាតផ្សេងៗរបស់សិស្សនៅក្នុងការរៀនសូត្រ ហើយនិងដើម្បីជួយផ្លាស់ប្តូរសិស្សឲ្យធ្វើដំណើរទៅកាន់ការបញ្ចប់ដ៏ជោគជ័យនូវក្នុងកម្មវិធីសិក្សានៅសាលាអ៊ិលម៉ាក់ ហើយនិងផ្តល់ឱកាសសំរាប់សិស្សដើម្បីនឹងអាចសម្រេចបានជោគជ័យក្នុងការសិក្សា, ការចេះប្រាស្រ័យទាក់ទងក្នុងសង្គម ហើយនិងការប្រកបការងារទៅថ្ងៃក្រោយផងដែរ ។*

*កម្មវិធី* ហ្វេស្សិះ *គឺមានកាលអនុវត្តន៍បី ឬបីដំណាក់ការដ៏សំខាន់ៗ ។ ដំណាក់កាលនិមួយៗ គឺរចនាឡើងដើម្បីផ្តល់ឲ្យសិស្សទាំងឡាយនូវភាពស្ទាត់ជំនាញដែលចាំបាច់ផ្សេងៗ ដើម្បីបំពេញដល់តម្រូវការទាំងឡាយនៃការបញ្ចប់ការសិក្សាប្រចាំរដ្ឋម៉ាស្សាឈូសែត ហើយនិងសំរាប់សាលារៀន មីដល់ស៊ិក អាខាឌីមី ឆាទើ នៃក្រុងឡូវែលផងដែរ ។*

*នៅក្នុង* ដំណាក់កាលអនុវត្តន៍ទីមួយ *សិស្សទាំងអស់ត្រូវខិតខំផ្តោតអារម្មណ៍ទៅលើការទាញយកនូវមុខវិជ្ជាជំនាញនានាដែលចាំបាច់សំរាប់ជួយសិស្សឲ្យបានជោគជ័យ ។*

*នៅក្នុង* ដំណាក់កាលអនុវត្តន៍ទីពីរ *សិស្សទាំងអស់ត្រូវខិតខំផ្តោតអារម្មណ៍ទៅលើការបង្ហាញនូវមុខវិជ្ជាជំនាញនានាដែលបានរៀនសូត្រមកពីដំណាក់កាលវិវត្តន៍ទីមួយរួចហើយ ។*

*នៅក្នុង* ដំណាក់កាលងនុវតន្តន៍ទីបី *សិស្សទាំងអស់ត្រូវខិតខំផ្តោតអារម្មណ៍ទៅលើអនុវត្តនូវវិជ្ជាជំនាញនានាដែលបានរៀនសូត្រមកពី ដំណាក់កាលវិវត្តន៍ទី១* និងទី២ *។*

*ដំណាក់កាលអនុវត្តន៍និមួយៗ  គឺមានរួមបញ្ចូលមុខវិជ្ជាសិក្សាដូចតទៅ ៖*

- *មានចំនួនប្រមាណ* 12  *មុខវិជ្ជាសិក្សាផ្សេងៗ*
- *មានរួមបញ្ចូលទាំងសមាសភាគសេវាកម្មប្រចាំសាលា និងសហគមន៍*
- *មានការបង្កើតផលប័ត្រ* (portfolio) *ហើយនិងការសិក្សាមេរៀនសារឡើងវិញផ្សេងៗ*

*វត្ថុត្រូវការសំរាប់ដំណាក់កាលអនុវត្តន៍ទី* ២ និងទី៣ មានរួមបញ្ចូល៖

- *ការរៀបចំហ្វឹកហ្វឺនផ្នែកអាជីពផ្សេងៗ*
- *ការស្ម័គ្រចិត្តសាកល្បងធ្វើកិច្ចការសង្គមផ្សេងៗ ឲ្យបាន* 50 *ម៉ោង*
- *មានឱកាសសំរាប់ចុះឈ្មោះចូលរៀនជាទ្វេគុណ* (Dual Enrollment)
- *ការប្រឡងចប់បានជោគជ័យខាងផ្នែក អ៊ិមខះ* (MCAS)
- *មានជំនាញការផ្នែកគណិតសាស្រ្ត និងភាសាអង់គ្លេស*
- *ការប្រឡងចប់បានជោគជ័យនូវថ្នាក់រៀនទាំងឡាយនៃ "ថ្នាក់ទីបំផុត" គឺថ្នាក់ទី១២*

*គឺមានពេលវេលាបីត្រីមាស ដែលនឹងត្រូវបានអនុញ្ញាតឲ្យបញ្ចប់ដំណាក់កាលអនុវត្តន៍និមួយៗ ។*

*ដំណើរការជឿនលឿននៃការសិក្សា គឺនឹងត្រូវបានគេពិនិត្យមើលនៅចុងត្រីមាសនិមួយៗ ។ សិស្សទាំងឡាយដែលមិនបានបញ្ចប់នូវដំណាក់អនុវត្តន៍ណាមួយក្នុងកំឡុងបីត្រីមាស នឹងត្រូវគេតម្រូវឲ្យរៀនសូត្រសារឡើងវិញនៅដំណាក់កាលអនុវត្តន៍មួយនោះ ឬនឹងត្រូវបានគេដកឈ្មោះចេញពីសាលារៀន ។*

*សំរាប់បញ្ជីមុខវិជ្ជាសិក្សាទាំងអស់របស់សាលារៀន អ៊ិលម៉ាក់ សូមមើលសៀវភៅបញ្ជីមុខវិជ្ជាសិក្សាបច្ចុប្បន្នរបស់យើង ។*

# វិន័យនិងច្បាប់ប្រតិបត្តិទាំងឡាយដែលមិនអាចតវ៉ាបាន
## (NON-NEGOTIABLE RULES AND POLICIES)

**វិន័យនិងច្បាប់ទាំងឡាយដែលមិនអាចតវ៉ាបាននៅសាលារៀន អ៊ិលម៉ាក់ (LMACS) គឺត្រូវបានបង្កើតឡើងដោយការគោរពដ៏ត្រឹមត្រូវ ៖**

**គោរពខ្លួនឯង៖**

*ដើម្បីជាសិស្សម្នាក់នៃសាលា, អ្នកត្រូវធ្វើកិច្ចការដែលផ្ដោះទៅលើគោលបំណងរបស់អ្នក សំរាប់នឹងអាចសម្រេចអនាគតដ៏មានជោគជ័យ និងមានសុខមាលភាពល្អ ។*

**គោរពអ្នកដទៃ៖**

*អ្នកត្រូវប្រព្រឹត្តចំពោះសិស្ស, បុគ្គលិកសាលាអ៊ិលម៉ាក់, បុគ្គលិកសាលាមហាវិទ្យាល័យ អ៊ិមស៊ីស៊ី ហើយនិងចំពោះភ្ញៀវទាំងឡាយរបស់សាលា ដោយភាពគួរសម និងដោយគោរពផងដែរ ។*

**គោរពកម្មសិទ្ធិអ្នកដទៃ៖**

*អ្នកត្រូវជួយថែរក្សាផ្ទៃបរិមាណសាលារៀនទាំងមូល, សាលាមហាវិទ្យាល័យ ហើយនិងរបស់កម្មសិទ្ធិនៃអ្នកដទៃ ។*

---

- *មិនត្រូវប្រើអំពើរឃោរឃៅ ឬការគំរាមគំហែងនៃអំពើរហឹង្សាណាមួយឡើយ ។ ការប៉ះទង្គិច ឬការមិនយល់ស្របគំនិតគ្នា អ្វីមួយគឺត្រូវដោះស្រាយគ្នាដោយសន្តិវិធី គឺដោយអំពើរអហឹង្សា ។ វាគឺជាបទល្មើសនៃច្បាប់រដ្ឋដែលកាន់អាវុធអ្វីមួយនៅ កន្លែងសាលា ឬនៅក្នុងពិធីផ្សេងៗដែលរៀបចំឡើងដោយសាលារៀន, មាត្រា* M.G.L.A. 71 § 37 H ។
- *គប្បីនិយាយស្ដីជាមួយអ្នកដទៃទៀតដោយការគោរព ៖ មិត្តរួមសាលា, បុគ្គលិកសាលាអ៊ិលម៉ាក់, បុគ្គលិកមហាវិទ្យាល័យ អ៊ិមស៊ីស៊ី, អ្នកជួលអាគារ និងភ្ញៀវទាំងឡាយ ។ គ្មានពាក្យថោកទាប ឬភាសាប្រមាថណាមួយនឹងត្រូវបានគេអនុញ្ញាតឡើយ ។*
- *ចូរជួយថែរក្សាទីធ្លាសាលាឲ្យបានស្អាតស្អំពីគ្រឿងញៀនផ្សេងៗ ។ មិនត្រូវឲ្យមានថ្នាំ ឬគ្រឿងញៀនប្រភេទណាមួយនៅក្នុងបរិវេណសាលា និងមហាវិទ្យាល័យឡើយ គឺគ្រប់ពេលវេលាទាំងអស់ជាកំហិត ។*
- *សិស្សមិនអាចជក់បារីនៅលើបរិវេណសាលារៀនឡើយ ។ នេះ គឺរួមបញ្ចូលទាំងនៅតាមមាត់ទ្វារ និងនៅតាមអង្កែលយចូលតាមជញ្ជាំងនានានៃអាគារសាលារៀនអ៊ិលម៉ាក់ផងដែរ ។ សិស្សដែលល្មើសនឹងបត់បំរាមជក់បារីនេះ នឹងត្រូវស្នើឲ្យចាកចេញពីសាលារៀនមួយថ្ងៃ ហើយនិងត្រូវដាក់ថាអវត្តមាននៅក្នុងថ្នាក់រៀនទាំងឡាយរបស់គេផងដែរ ។* **វាគឺជាបទល្មើសច្បាប់ប្រចាំរដ្ឋដែលជក់បារីនៅក្នុងបរិវេណសាលារៀននានា ។**
- *សិស្សមិនអាចចាកចេញពីអាគារសាលារៀនបាននៅក្នុងពេលសិក្សាដោយគ្មានការអនុញ្ញាតឡើយ ។ សិស្សណាដែលចាកចេញពីអាគារសាលា ដោយគ្មានការអនុញ្ញាត នឹងត្រូវគេបញ្ជូនទៅផ្ទះសំរាប់ថ្ងៃនោះ ហើយនិងត្រូវទទួលការកត់ ថាអវត្តមានមួយនៅក្នុងថ្នាក់រៀនរបស់ពួកគេ ។*
- *ត្រូវរៀបចំខ្លួនជាស្រេចសំរាប់ថ្នាក់រៀនទាំងឡាយ ។*
  - *ត្រូវយកសៀវភៅកត់កំណោរដែលមាន ៥ មុខវិជ្ជាមកជាមួយអ្នកនៅគ្រប់ថ្នាក់រៀនទាំងឡាយ ។*
  - *មិនអនុញ្ញាតឲ្យប្រើទូរស័ព្ទដៃនៅក្នុងកន្លែងណាមួយនៃអាគារសាលារៀនឡើយ ។ បើសិស្សណាល្មើសនឹងបទបំរាមនេះ គឺថាទូរស័ព្ទរបស់គេនឹងត្រូវបុគ្គលិកដកហូតយក ហើយអ្នកអាណាព្យាបាលសិស្សនឹងត្រូវបានទទួលដំណឹងនោះដែរ ។ ការល្មើសជាច្រើនដង នឹងត្រូវទទួលការពិន័យ ដែលអាចរហូតដល់ត្រូវដេញចេញឲ្យឈប់ រៀនពីសាលាផងដែរ ។*
  - *មិនត្រូវនាំយកអាហារ ឬភេសជ្ជៈចូលទៅក្នុងថ្នាក់រៀនឡើយ ។*
  - *គប្បីត្រូវស្លៀកពាក់ឲ្យបានត្រឹមត្រូវសំរាប់សាលារៀន ។*
- *គប្បីត្រូវគោរពបរិវេណសាលារៀន អ៊ិលម៉ាក់, មហាវិទ្យាល័យ អ៊ិមស៊ីស៊ី ហើយនិងទីធ្លាអាគារសាលាទាំងមូលផងដែរ ។*
  - *មិនត្រូវធ្វើឲ្យខូចរូបរាង ឬសរសេរ ឬគូរគំនូរអ្វីនៅលើជញ្ជាំងនៃអាគារសាលារៀនឡើយ ។*
  - *ត្រូវចោលសំរាមទាំងអស់នៅក្នុងធុងសំរាមឲ្យបានល្អត្រឹមត្រូវ ។*

# ច្បាប់ប្រតិបត្តិផ្សេងៗនៃវិន័យ
# DISCIPLINARY POLICIES

ច្បាប់សំរាប់ដាក់វិន័យទណ្ឌកម្មផ្សេងៗនៃសាលារៀន អ៊ិលម៉ាក់ គឺត្រូវបានបង្កើតឡើយដើម្បីជួយគាំទ្រនូវសេចក្តីសុចរិតនៃសហគមន៍សាលារៀន អ៊ិលម៉ាក់ទាំងមូល ហើយនិងជួយទ្រទ្រង់ដល់សិស្សទាំងឡាយក្នុងការគោរពតាមវិន័យនិងច្បាប់ទាំងឡាយដែលមិនអាចផ្លាស់ប្តូរបាននៃសាលារៀន អ៊ិលម៉ាក់ ដូចបានថ្លែងនៅខាងលើ ។ កំរិតប្រសិទ្ធិភាពនៃការធ្វើអត្តពគមន៍នឹងជួយផ្តល់ឲ្យសិស្សអាចបង្ហាញឲ្យឃើញឡើងវិញនូវអាកប្បកិរិយារបស់ពួកគេ ។ សិស្សទាំងឡាយដែលប្រឈមមុខនឹងភាពលំបាកនានាក្នុងការអនុវត្តន៍ឲ្យបានត្រឹមត្រូវតាមច្បាប់ នឹងត្រូវបានគេបញ្ជូនឲ្យទៅជួបនឹង **បុគ្គលិកទទួលបន្ទុកខាងផ្នែកធ្វើអត្តពគមន៍នៃសាលា អ៊ិលម៉ាក់** ។ បើសិនជាអាកប្បកិរិយារបស់សិស្សនោះនៅមិនផ្លាស់ប្តូរ បន្ទាប់ពីបុគ្គលិកសាលាបានធ្វើអត្តពគមន៍ហើយនោះ ឬក៏អាកប្បកិរិយានោះត្រូវបានកំណត់ដោយអគ្គនាយកសាលាថាត្រូវការជំនួយបន្ថែមលើការធ្វើអត្តពគមន៍ថែមទៀតនោះ គឺត្រូវបញ្ជូនដល់**គណៈកម្មការត្រួតពិនិត្យអកិសមាចារនៃសាលាអ៊ិលម៉ាក់** ដើម្បីឲ្យគេធ្វើការពិនិត្យវិនិច្ឆ័យមើលឲ្យបានត្រឹមត្រូវ ។ បទល្មើសលើសិទ្ធិពលរដ្ឋ, សស្ត្រាវុធ, ថ្នាំញៀន ហើយនិងអំពើរឃោរឃៅផ្សេងៗ គឺចាំបាច់ត្រូវការចាត់ចែងដោយអគ្គនាយកសាលាភ្លាមៗ ហើយមិនចាំបាច់អនុវត្តន៍តាមដំណើរការច្បាប់ដាក់វិន័យទូទៅរបស់សាលារៀន អ៊ិលម៉ាក់ ឡើយ ។ បទល្មើសហើយនិងដំណើរការដាក់វិន័យពិសេសទាំងឡាយនោះ គឺត្រូវបានចែងយ៉ាងច្បាស់លាស់នៅខាងវគ្គ ឬមាត្រាក្រោយបន្តិចទៀតនៅក្នុងសៀវភៅណែនាំនេះ ។

សិស្សទាំងអស់ គឺត្រូវបានគេសង្ឃឹមថានឹងអាចប្រព្រឹត្តបានល្អតាមតម្រូវការទាំងឡាយសំរាប់អាកប្បកិរិយាដូចដែលបានចែងនៅក្នុងកូនសៀវភៅណែនាំនេះ ។ មាត្រា 71B នៃច្បាប់ទូទៅប្រចាំរដ្ឋម៉ាស្សាឈូសែត ដែលគេតែងបានស្គាល់ជាទូទៅថា មាត្រា 766 គឺតម្រូវឲ្យមានការផ្លាស់ប្តូរផ្សេងៗបន្ថែមទៀត សំរាប់សិស្សណាដែលត្រូវបានគេពិនិត្យឃើញដោយគណៈកម្មការថា មានការត្រូវការជំនួយពិសេសនានា ហើយដែលកម្មវិធីនោះត្រូវបានអធិប្បាយនៅក្នុងកម្មវិធីសិក្សាផ្ទាល់ខ្លួនពិសេស ឬកម្មវិធី អាយអ៊ីភី (IEP-Individualized Educational Plan) ។ ចំពោះសិស្សទាំងឡាយណាដែលរៀនក្នុងកម្មវិធី អាយអ៊ីភីដែលត្រូវបានគេបញ្ឈប់ឲ្យរៀន ១០ថ្ងៃ ឬច្រើនថ្ងៃនៅក្នុងមួយឆ្នាំសិក្សា, ចាំបាច់ត្រូវរៀបចំធ្វើតាមនីតិវិធីទម្រង់ការដូចតទៅ ៖

1. រៀបចំកោះហៅអង្គប្រជុំគណៈកម្មការទាំងមូល ។
2. ត្រូវពិចារណានូវសេចក្តីត្រូវការសំរាប់ធ្វើការសាកល្បងបន្ថែមផ្សេងៗ ។
3. ត្រូវធ្វើការកំណត់ពីអ្វីៗដែលបង្ហាញឲ្យឃើញ ។
4. ត្រូវធ្វើការវិនិច្ឆ័យដល់អាកប្បកិរិយាផ្សេងៗ (បើសិនជាមានការបញ្ឈប់ច្រើនជាង ១០ថ្ងៃ) ។
5. ត្រូវបង្កើតនូវគម្រោងអត្តពគមន៍ផ្នែកជំនួយអាកប្បកិរិយាមួយ បន្ទាប់ពីធ្វើការវិនិច្ឆ័យដល់អាកប្បកិរិយាផ្សេងៗ (សូមពិនិត្យមើលគម្រោងការណ៍ បើសិនជាមានហើយនោះ) ។
6. ត្រូវកែតម្រូវនូវកម្មវិធី អាយអ៊ីភី បើសិនជាយល់ថាសមរម្យ ។

## បុគ្គលិកអន្តរាគមន៍
## STAFF INTERVENTION

*បើសិនជា, បន្ទាប់ពីការពិគ្រោះពិភាក្សាគ្នាជាច្រើនដងហើយ អាកប្បកិរិយាសិស្សនៅតែមិនផ្លាស់ប្តូរបានប្រសើរឡើងទេនោះ, ការប្រជុំជាមួយនឹងបុគ្គលិកទទួលបន្ទុកធ្វើអន្តរាគមន៍នឹងកើតមានឡើង ។ ដោយហេតុថា សាលាអ៊ិលម៉ាក់មានជំនឿថាសិស្សទាំងអស់មានសេចក្តីប្រាថ្នាចង់រៀនសូត្រឲ្យបានជោគជ័យគ្រប់ៗគ្នា, បុគ្គលិកទទួលបន្ទុកធ្វើអន្តរាគមន៍នឹងផ្តោតអារម្មណ៍ទៅលើការពន្យល់ឲ្យបានច្បាស់លាស់ពីការសង្ឃឹមនានារបស់សាលារៀន និងជួយស្រាវជ្រាវជាមួយសិស្សនូវឧបសគ្គផ្សេងៗ ដែលរារាំងសិស្សមិនអាចអោយបានទទួលជោគជ័យនៅសាលា ។ បើសិនជាអាកប្បកិរិយាសិស្សនៅតែមិនផ្លាស់ប្តូរបានប្រសើរឡើងទេ បន្ទាប់ពីការអន្តរាគមន៍របស់បុគ្គលិកសាលានោះ គឺថាចំណង់រកហេតុផលរបស់សិស្សដែលចង់រៀនឲ្យបានជោគជ័យនៅសាលាអ៊ិលម៉ាក់នោះ គឺនឹងត្រូវបានគេមានការចាប់សង្ស័យជាខ្លាំង  ហើយការពិនិត្យសើរើលើការអភិសមាចារ* (Ethical Review) *ក៏នឹងត្រូវបានគេរៀបចំធ្វើឡើងផងដែរ ។*

## ការពិនិត្យវិនិច្ឆ័យអភិសមាចារ
## ETHICAL REVIEW

*ការពិនិត្យវិនិច្ឆ័យអភិសមាចារ គឺជាអង្គប្រជុំចុងក្រោយបំផុត (គឺមានភាពប្រហាក់ប្រហែលគ្នានឹងការអង្គជំនុំជម្រះ) សំរាប់សិស្សទាំងឡាយណាដែលប្រឈមមុខនឹងការលំបាកដដែលៗច្រើនលើកច្រើនសារ ទាក់ទងនឹងការមកចូលរៀន, ការមកចូលរៀនយឺតយាវដែលទាក់ទងទៅនឹងការរៀនធ្លាក់ថ្នាក់ផ្សេងៗ ហើយនិងឬក៏ដែលទាក់ទងនឹងអាកប្បកិរិយានៅក្នុងថ្នាក់រៀន ។ សិស្សនឹងត្រូវបង្ហាញខ្លួននៅចំពោះមុខគណៈកម្មការពិនិត្យវិនិច្ឆ័យអភិសមាចារនៅលើកទីបី ចំពោះសិស្សណាដែលមានបញ្ហាជាមួយការចូលរៀន, ការយឺតយាវដែលទាក់ទងទៅនឹងការរៀនធ្លាក់ថ្នាក់ ឬមានបង្ហាញអាកប្បកិរិយាផ្សេងៗ ។ សិស្សក៏ប្រហែលជានឹងត្រូវបង្ហាញខ្លួនចំពោះមុខគណៈកម្មការផងដែរ សំរាប់អាកប្បកិរិយាដែលប្លែកពីធម្មតា ដូចជាការវាយតប់គ្នា, មានកាន់គ្រឿងអាវុធ ឬគ្រឿងញៀនផ្សេងៗ, មានការចោលពាក្យសំដីគំរាមគំហែងដល់បុគ្គលិកសាលា ឬដល់សិស្សដទៃទៀត ហើយនិងមានភាពឃោរឃៅ ឬការសំលុតឈ្លានពានទៅកាន់បុគ្គលិក ឬសិស្សដទៃទៀតនោះ ។*

*សិស្សណាដែលត្រូវបានគេបញ្ជូនឲ្យទៅជួបគណៈកម្មការពិនិត្យវិនិច្ឆ័យអភិសមាចារ នឹងបានទទួលដំណឹងជាមុន ។ នៅពេលដែលបានទទួលដំណឹងនេះហើយ សិស្ស ឬមាតាបិតា, អ្នកអាណាព្យាបាល, អ្នកទទួលបន្ទុក (បើសិនជាសិស្សនោះនៅក្រោមអាយុ ១៨ឆ្នាំ) នឹងត្រូវប្រាប់ដល់គណៈកម្មការពិនិត្យវិនិច្ឆ័យអភិសមាចារ ថាតើពួកគេអាចមកជួបប្រជុំតាមថ្ងៃខែដែលបានកំណត់នោះដែរឬទេ ។  បើសិនជាសិស្សមិនបានប្រាប់ទៅគណៈកម្មការពិនិត្យវិនិច្ឆ័យអភិសមាចារ ថាតើខ្លួននឹងមិនអាចមកប្រជុំដូចតាមថ្ងៃខែកំណត់ ឬក៏មិនបានមកទេនោះ, នេះនឹងសបញ្ជាក់ឲ្យឃើញថា ចំណាប់អារម្មណ៍របស់សិស្សក្នុងការមកបន្តការសិក្សានៅសាលាអ៊ិលម៉ាក់ នឹងអាចមានបញ្ហា ហើយនាយកសាលាមានសិទ្ធិដេញសិស្សឲ្យចេញពីសាលាបាន ។*

*នៅឯអង្គប្រជុំនៃគណៈកម្មការពិនិត្យវិនិច្ឆ័យអភិសមាចារ  សិស្សនឹងត្រូវបានគេណែនាំប្រាប់ឲ្យសមាជិកម្នាក់ៗបានស្គាល់ ។ មូលហេតុនានានៃការបញ្ជូនក៏នឹងត្រូវបានគេអធិប្បាយផងដែរ ។ សិស្សនឹងត្រូវបានគេផ្តល់ឧកាសឲ្យនិយាយចំពោះបញ្ហានា*

*នាពីអវត្តមាន, ការគេចមិនចូលសាលាដែលទាក់ទងទៅនឹងការរៀនថ្នាក់ថ្នាក់ ឬពីអាកប្បកិរិយានៅក្នុងសាលាឬថ្នាក់រៀន ហើយនិងពន្យល់ពីការសម្របសម្រួលនូវស្ថានភាពអ្វីផ្សេងៗផងដែរ ។ សិស្សនឹងត្រូវបានគេស្នើឲ្យចេញពីបន្ទប់ប្រជុំ នៅក្នុងខ:ណ:ដែលគណ:កម្មការពិនិត្យវិនិច្ឆ័យអភិសមាចារត្រូវការពិភាក្សាជំនុំជម្រះសេចក្តី ។ សិស្សនឹងត្រូវបានគេហៅឲ្យចូលទៅកាន់បន្ទប់ប្រជុំវិញ ហើយការសម្រេចចិត្តរបស់គណ:កម្មការ ហើយនិងហេតុផលដែលកើតឡើងជាបន្តបន្ទាប់ទាំងឡាយ នឹងត្រូវបានគេជំរាបប្រាប់ផងដែរ ។ ថែមទៅលើចលនាណែនាំកែតម្រូវទាំងឡាយដែលបានសំរេចឡើងដោយគណកម្មការ, ការដាក់ពិន័យទណ្ឌកម្មទាំងឡាយ, ឧទាហរណ៍ដូចជាការបញ្ឈប់ ឬការបណ្តេញចេញពីសាលារៀន នឹងត្រូវបានគេចាប់ផ្តើមអនុវត្តន៍ឡើងផងដែរ ។ សិស្សហើយនិងអ្នកអាណាព្យាបាល នឹងបានទទួលដំណឹងបន្ថែមទៀត ជាលាយលក្ខអក្សរស្តីពីការសំរេចចិត្តរបស់គណ:កម្មការ ក្នុងរយ:ពេលប្រាំពីរថ្ងៃនៃការប្រជុំរបស់គណ:កម្មការពិនិត្យវិនិច្ឆ័យអភិសមាចារ ។*

*ការសំរេចចិត្តរបស់គណកម្មការពិនិត្យវិនិច្ឆ័យអភិសមាចារ ក៏អាចនឹងសុំតវ៉ាបានដោយសិស្សផ្ទាល់ ឬដោយអ្នកអាណាព្យាបាលទៅកាន់នាយកសាលា ។ ការស្នើសុំដោយលាយលក្ខអក្សរសំរាប់ការសុំតវ៉ា នឹងត្រូវដាក់ស្នើទៅកាន់នាយកសាលាក្នុងរយ:ពេលប្រាំពីរ (៧) ថ្ងៃនៃការផ្តល់ដំណឹងពីការសំរេចចិត្តនោះ ។ នាយកសាលានឹងពិនិត្យពិចារណានូវការស្នើសុំតវ៉ានេះ ហើយនិងចេញនូវការសំរេចចិត្តជាលាយលក្ខអក្សរក្នុងរយ:ពេលប្រាំពីរថ្ងៃ ។*

*នាយកសាលាមានសិទ្ធិគ្រប់គ្រាន់នឹងបណ្តេញសិស្សទាំងឡាយណាដែលមានថ្នាំញៀន, សាស្ត្រាវុធ ឬអំពើរំលោភឃោរឃៅ ឬការគំរាមកំហែងដល់បុគ្គលិកណាម្នាក់ ដូចបានថ្លែងនៅក្នុងច្បាប់មាត្រា* M.G. Lc. 71, § 37H (a) *និង* (b) *ស្រាប់ ។*

*នៅក្នុងករណីដែលទាក់ទងនឹងការបណ្តេញចេញពីសាលា, សិស្សហើយនិងអ្នកអាណាព្យាបាលមានសិទ្ធិសុំតវ៉ាទាមទារដោយផ្ទាល់ទៅកាន់សមាជិកក្រុមប្រឹក្សានៃសាលារៀន អ៊ិលម៉ាក់ ។ សិស្សដែលបានគេដេញចោលនោះ នឹងមានរយ:ពេលដប់ (១០)ថ្ងៃ ពីថ្ងៃដែលគេបណ្តេញចេញពីសាលារៀននោះ ដើម្បីនឹងប្រាប់ទៅក្រុមប្រឹក្សានៃសាលា អ៊ិលម៉ាក់ ពីការសុំតវ៉ារបស់ខ្លួន ។ សិស្សមានសិទ្ធិគ្រប់គ្រាន់ក្នុងការទទួលវិនិច្ឆ័យដ៏ត្រឹមត្រូវតាមច្បាប់ រួមបញ្ចូលទាំង ក)សំបុត្រសរសេរនៃការដេញចេញពីសាលា, ខ)ពេលវេលាគ្រប់គ្រាន់ដើម្បីរៀបចំដាក់ពាក្យសុំតវ៉ា, គ)មានសិទ្ធិអាចមានតំណាងដោយមេធាវី ឬដោយអ្នកជំនួយទាមទារណាផ្សេងទៀតដែលសិស្សអាចបង់ថ្លៃបាន, ឃ)មានសិទ្ធិអាចបង្ហាញភស្តុតាងនិងអ្នកសាក្សីផ្សេងៗ, ង)មានសិទ្ធិអាចសាកសួរអ្នកសាក្សីទាំងឡាយដែលប្រឆាំងនឹងសិស្ស ហើយនិងអាចទទួលការសំរេចចិត្តជាលាយលក្ខអក្សរដោយឆាប់រហ័សបំផុតតាមដែលអាចធ្វើទៅបាន ដែលរួមមានបញ្ចូលទាំងកត្តាផ្សេងៗសំរាប់ការសំរេចចិត្តទាំងឡាយនោះ ។*

## នីតិវិធីនានាសម្រាប់រាយការណ៍ និងការឆ្លើយតបទៅនឹងឧបត្តិហេតុផ្សេងៗនៃការរំលោភសិទ្ធិស៊ីវិលទាំងឡាយ

## PROCEDURES FOR REPORTING AND RESPONDING TO INCIDENTS OF CIVIL RIGHTS VIOLATIONS

*សាលា* មុីដល់សុិក អាខាឌីមុី ឆាទើ *ប្តេជ្ញាចិត្តដើម្បីថែរក្សាបរិវេណសាលារៀន និងកន្លែងធ្វើការដែលពោរពេញទៅដោយភាពសេរីដែលគ្មានការរំខានរុកគួននិងការប្រកាន់រើសអើងដោយពូជសាសន៍, ពណ៌សម្បុរ, ភេទ, សាសនា, ប្រភពសញ្ជាតិដើម*

*កំណើត, លំដាប់ផ្លូវភេទ ហើយនិងពិការភាពអ្វីឡើយ ។ សាលាអ៊ិលម៉ាក់ សង្ឃឹមថាសមាជិកទាំងអស់នៃសហគមន៍សាលារៀន ដែលមានរួមបញ្ចូលទាំងគណៈក្រុមប្រឹក្សា, គណៈដឹកនាំ, គណៈសាស្ត្រាចារ្យ, បុគ្គលិក, អ្នកស្ម័គ្រចិត្ត ហើយនិងសិស្សទាំងអស់ នឹងប្រព្រឹត្តយកនូវចរិយាសម្បត្តិដ៏ថ្លៃថ្នូរ ដែលនឹងជៀសផុតស្រឡះពីអាកប្បកិរិយាបែបប្រកាន់រើសអើងទាំងឡាយដាក់ជាមិនខានឡើយ ។ បើសិនជាសិស្សណាម្នាក់បានទទួលបទពិសោធន៍, ប្រទះឃើញ ឬក្រុមទីប្រឹក្សាណាមួយរាយការណ៍ពីការរំខានរុកគួន ឬពីអំពើប្រកាន់ពូជសាសន៍អ្វីមួយ, សិស្សនោះត្រូវរាយការណ៍ប្រាប់ទៅដល់នាយកសាលាភ្លាម ។ ការស៊ើបអង្កេតពីឧបត្តិហេតុនោះ នឹងត្រូវចាប់ផ្តើមធ្វើឡើងភ្លាមៗ ទៅតាមលក្ខណៈនៃបទនីតិវិធីដែលបានចែងយ៉ាងលំអិតនៅក្នុង* កូនសៀវភៅស្តីពីសិទ្ធិស៊ីវិល និងច្បាប់មិនប្រកាន់ពូជសាសន៍ *ទាំងឡាយរបស់សាលារៀនអ៊ិលម៉ាក់ នោះស្រេច ។*

## ច្បាប់ប្រតិបត្តិទាំងឡាយដែលទាក់ទងនឹងទោសកម្មផ្សេងៗ
## POLICIES RELATED TO SPECIFIC OFFENSES

*សិស្សណាម្នាក់ដែលបានចុះឈ្មោះចូលរៀននៅក្នុងសាលារៀន* ម៉ីដល់ស៊ិក អាខាឌីមី ឆាទើ *នឹងមិនអាចមកកាន់បរិវេណសាលារៀន ឬចូលរួមនឹងកម្មវិធីនានាដែលរៀបចំឡើងដោយសាលាបានឡើយ (រួមបញ្ចូលទាំងកម្មវិធីកីឡាទាំងឡាយផងដែរ) បើះ*

**ក) បំពារបំពាន ឬវាយប្រហារដល់សមាជិកនៃបុគ្គលិកសាលា ឬសិស្សណាម្នាក់**

**ខ) មានសាស្ត្រាវុធអ្វីមួយ គឺរួមបញ្ចូលទាំងកាំភ្លើង, កាំបិត, ដំបង, ចំពាមកៅស៊ូ ឬក៏វត្ថុផ្សេងៗដែលអាចមានភាពគ្រោះថ្នាក់,**

**គ) បំផ្លាញយ៉ាងសាហាវព្រៃផ្សៃដល់ទ្រព្យសម្បត្តិផ្ទាល់ខ្លួន ឬទ្រព្យរបស់មហាវិទ្យាល័យ ម៉ីដល់ស៊ិក ឬសាលារៀន ម៉ីដល់ស៊ិក អាខាឌីមី ឆាទើ ឬដល់សមាជិកណាម្នាក់នៃសាលារៀន,**

**ឃ) ធ្វើការគំរាមគំហែងដាក់គ្រាប់បែក ឬធ្វើភាវវៈអគ្គីភ័យ, ប្រព្រឹត្តអំពើអគ្គិភ័យ ឬមានគ្រឿងជាតិផ្ទុះផ្សេងៗ ។**

*បទល្មើសប្រភេទណាមួយដូចខាងលើនេះ នឹងបណ្តាលឲ្យមានការបញ្ឈប់ពីសាលារៀនដប់ (១០) ថ្ងៃភ្លាមៗ ហើយនិងការពិនិត្យវិនិច្ឆ័យអភិសមាចារ ក៏នឹងចាប់ផ្តើមរៀបចំចាត់ចែងធ្វើភ្លាមៗផងដែរ ។ ការពិនិត្យវិនិច្ឆ័យអភិសមាចារ គឺជាអង្គប្រជុំជំនុំជំរះដេញចេញពីសាលា យោងទៅតាមច្បាប់ប្រតិបត្តិរដ្ឋម៉ាស្សាឈូសែត* M.G.L. *មាត្រា* C.71 S.37H (a) (b) ។

*ម៉្យាងវិញទៀត, នាយកសាលាក៏មានសិទ្ធិអាចដេញសិស្សទាំងឡាយណាដែលមានថ្នាំគ្រឿងញៀន, អាវុធ ឬការបំពារបំពានលើបុគ្គលិកណាម្នាក់ យោងទៅតាមច្បាប់ប្រតិបត្តិនៃរដ្ឋម៉ាស្សាឈូសែត* M.G. L.*មាត្រា* C. 71, § 37H (a) *និង* (b)។

## នីតិវិធីបណ្តឹងឧទ្ធរណ៍
## APPEALS PROCEDURE

*ក្នុងករណីទាំងឡាយណាដែលទាក់ទងនឹងការបណ្តេញចេញពីសាលារៀន, សិស្សមានសិទ្ធិប្តឹងតវ៉ាទៅក្រុមប្រឹក្សានៃសាលារៀន អ៊ិលម៉ាក់ បានដោយផ្ទាល់ ។ សិស្សដែលគេដេញចេញនោះ នឹងមានរយៈពេលដប់ (១០) ថ្ងៃចាប់ពីថ្ងៃដែលសាលាដេញចេញនោះ ដើម្បីផ្តល់ដំណឹងដល់ក្រុមប្រឹក្សាសាលាអំពីបណ្តឹងតវ៉ា ឬបណ្តឹងឧទ្ធរណ៍របស់ខ្លួន ។ សិស្សមានសិទ្ធិគ្រប់គ្រាន់ដើម្បីទាមទារការវិនិច្ឆ័យដ៏ត្រឹមត្រូវ ដែលមានរួមបញ្ចូលទាំង ក) សំបុត្រលាយលក្ខអក្សរពន្យល់ពីបទបណ្តេញ, ខ) ពេល*

*វេលាគ្រប់គ្រាន់ ដើម្បីរៀបចំសំរាប់ការកាត់ក្តី, គ) សិទ្ធិគ្រប់គ្រាន់ក្នុងការតាំងតំណាងក្តីដោយមេធាវី ឬអ្នកជួយទាមទារសិទ្ធិឲ្យសិស្សណាផ្សេងទៀតដែលបង់លុយកាក់ដោយសិស្សផ្ទាល់, ឃ) មានសិទ្ធិបង្ហាញភស្តុតាងនិងសាក្សីផ្សេងៗ, ង)មានសិទ្ធិសាកសួរដល់សាក្សីដែលប្រឆាំងនឹងសិស្ស, ហើយនិង ច)ទទួលនូវការសំរេចចិត្តជាលាយលក្ខអក្សរក្នុងរយៈពេលដ៏ឆាប់ ស្តីពីបទចោទប្រកាន់សំរាប់ការកាត់សេចក្តីទាំងនោះ ។*

*កម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍នោះ នឹងមិនគ្រាន់តែត្រូវកំណត់ទៅលើការសំរេចពិតប្រាកដ ថាតើសិស្សនោះបានប្រព្រឹត្តល្មើសនឹងច្បាប់ទាំងឡាយនោះឡើយ ។*

## **វត្តមានក្នុងថ្នាក់រៀន, ល័ក្ខខ័ណ្ឌពន្យារការសិក្សា, ការបញ្ឈប់ និងការបណ្តេញចេញ**
## **ATTENDANCE, ACADEMIC PROBATION, SUSPENSION & EXPULSION**

### ច្បាប់ប្រតិបត្តិអវត្តមាន *Absence Policy*

*អវត្តមានច្រើនជាងប្រាំមួយ (៦) ដងក្នុងថ្នាក់មួយនៅក្នុងមួយត្រីមាស គឺមានច្រើនហួសកំណត់មែនទែន ។ នេះមានន័យថាសិស្សបានបាត់បង់នូវការចូលរៀននៅក្នុងថ្នាក់ដែលត្រូវការជាចាំបាច់ ដែលមិនអាចរៀនសារជាថ្មីឡើងវិញបានឡើយ បើយោងទៅតាមនិយមន័យសិក្សា ព្រោះវាជាបទពិសោធន៍ធម្មតានៃកម្មវិធីបង្ហាត់បង្រៀននៃសាលារៀន អុិលម៉ាក ។ អវត្តមានរបស់សិស្ស គឺមិនគ្រាន់តែតម្រូវការប៉ុណ្ណោះទេ ប៉ុន្តែវាចាំបាច់ក្នុងការបង្រៀនហើយនិងលក្ខណៈសិក្សាផ្សេងៗទៀតផងដែរ ។*

*សិស្សម្នាក់ៗត្រូវទូរស័ព្ទមកលេខ* 978-656-3165 *ដើម្បីជំរាបប្រាប់សមាជិកសាលារៀន អុិលម៉ាក់ ឲ្យបានមុនម៉ោង* 9:00 *ព្រឹក បើសិនគេមិនអាចមកចូលរៀននៅថ្ងៃនោះទេ ។*

*ទន្ទឹមនឹងនេះ, សិស្សគប្បីមករៀនសួត្រសំរាប់ថ្នាក់និងសកម្មភាពទាំងឡាយឲ្យបានមុនម៉ោងចូលរៀន ដើម្បីនឹងឲ្យពួកគេអាចមានពេលវេលាគ្រប់គ្រាន់នៅពេលដែលគេចាប់ផ្តើមថ្នាក់រៀន ឬក៏សិក្សាពីសកម្មភាពអ្វីមួយ ។*

*អវត្តមានទាំងឡាយនឹងបូកបញ្ចូលពីឆមាសមួយទៅឆមាសមួយទៀត ។ សិស្សម្នាក់ៗចាប់ផ្តើមជាមួយនឹងការចូលរៀនក្នុងថ្នាក់ដ៏ល្អត្រឹមត្រូវ ហើយតួនាទីសំរាប់រក្សាបញ្ជីចូលរៀននេះ គឺស្ថិតនៅលើជំរើសរបស់សិស្សម្នាក់ៗតែប៉ុណ្ណោះ ។*

### សិទ្ធិតវ៉ារបស់សិស្ស *Student Appeals*

*សិស្សទាំងឡាយនឹងត្រូវគេអនុញ្ញាតឲ្យប្តឹងតវ៉ាសំរាប់ឥណទានពិន្ទុសិក្សា, ថ្នាក់រៀនផ្សេងៗដែលពួកគេបានប្រមូលរវាងប្រាំមួយ (៦) ទៅ ដប់ (១០) អវត្តមាន ហើយដែលបានទទួលពិន្ទុជាប់ថ្នាក់ (៧០% ឬល្អជាង)។ សិស្សទាំងឡាយអាចតវ៉ាទាមទារបានតែម្តងគត់ក្នុងកំឡុងពេលដែលគេចុះឈ្មោះចូលរៀននៅសាលារៀន អុិលម៉ាក់ ។ សិស្សត្រូវសរសេរសំបុត្រតវ៉ានោះទៅកាន់នាយកសាលាដោយផ្ទាល់ សំរាប់សុំទាមទារយកថ្នាក់នានាដែលពួកគេមានអវត្តមានហួសកំរិត ។ នៅក្នុងសំបុត្រនោះសិស្សត្រូវពន្យល់ឲ្យបានច្បាស់លាស់ពីមូលហេតុអ្វីដែលខ្លួនត្រូវទទួលយកនូវឥណទានសិក្សាសំរាប់ថ្នាក់រៀនទាំងឡាយ ។*

## លក្ខខ័ណ្ឌពន្យារការសិក្សា *Academic Probation*

*នាយកសាលានឹងដាក់សិស្សទាំងឡាយណាដែលបានមានពិន្ទុ " R" ពីរ (ពិន្ទុធ្លាក់ថ្នាក់រៀនច្រើនជង) ឬច្រើនជាងនៅក្នុងការប្រឡងយកពិន្ទុមួយលើកៗ, លក្ខខ័ណ្ឌព្យួរការសិក្សាណាមួយនៅក្នុងចន្លោះពេលប្រាំពីរ (៧) ថ្ងៃនៃការផ្តល់ដំណឹងដោយអ្នកប្រឹក្សា ឬអភិរក្សរបស់សិស្ស ។ ពិន្ទុរៀនធ្លាក់ថ្នាក់ គឺជាពិន្ទុទាំងឡាយដែលតិចជាង ៧០% ឬដែលមានអវត្តមានច្រើនជាងប្រាំ (៥)ដង ។*

*លើកទីពីរដែលសិស្សត្រូវដាក់លក្ខខ័ណ្ឌពន្យារការសិក្សា, នាយកសាលានឹងកោះហៅបុគ្គលិកធ្វើអត្តាគមន៍ ។ មាតាបិតា, អ្នកអាណាព្យាបាល, អ្នកទទួលបន្ទុកថែរក្សារបស់សិស្សនឹងត្រូវបានគេជំរាបប្រាប់ជាដំណឹងអោយដឹងផងដែរ ។*

*លើកទីបីដែលសិស្សត្រូវដាក់លក្ខខ័ណ្ឌពន្យារការសិក្សា, នាយកសាលានឹងកោះហៅអង្គប្រជុំរវាងសិស្ស, មាតាបិតា, អ្នកអាណាព្យាបាល, ឬអ្នកទទួលបន្ទុក ហើយនិងគណៈកម្មការវិនិច្ឆ័យអភិសមារចារ ។ នៅក្នុងអង្គវិនិច្ឆ័យអភិសមាចារ, សិស្សអាចស្នើសុំឲ្យយល់ព្រមនឹងលក្ខខ័ណ្ឌផ្សេងៗនៃកត្តាណាមួយដែលនឹងតម្រូវឲ្យធ្វើជាចាំបាច់ បើសិនពួកគេនឹងបន្តតួនាទីរបស់ខ្លួនជាសិស្សនៅសាលារៀន អ៊ិលម៉ាក់ នោះបន្តទៅទៀត ។*

*ការសំរេចចិត្តនៃអង្គប្រជុំរបស់បុគ្គលិកនិងសិស្ស ហើយនិងគណៈកម្មការវិនិច្ឆ័យអភិសមាចារ នឹងអាចសុំប្តឹងតវ៉ាទាមទារដោយសិស្សទៅកាន់នាយកសាលាបានផងដែរ ។ ក្រដាសលាយលក្ខអក្សរស្នើរសុំតវ៉ាទាមទារត្រូវផ្ញើទៅឲ្យនាយកសាលាក្នុងរយៈពេលប្រាំពីរ (៧)ថ្ងៃ បន្ទាប់ពីបានទទួលនូវការផ្តល់ដំណឹងនៃការសំរេចចិត្តបណ្តេញចោលពីសាលារៀន ។*

*នៅក្នុងករណីដែលទាក់ទងនឹងការបណ្តេញចេញពីសាលារៀន, សិស្សមានសិទ្ធិដើម្បីតវ៉ាទាមទារដោយផ្ទាល់ទៅកាន់ក្រុមប្រឹក្សានៃសាលារៀន អ៊ិលម៉ាក់ ។ សិស្សដែលគេដេញចេញនោះ នឹងមានពេលដប់ (១០)ថ្ងៃ ពីពេលដែលគេបណ្តេញចេញនោះ ដើម្បីប្រាប់ទៅក្រុមប្រឹក្សាសាលារៀន អ៊ិលម៉ាក់ ពីពាក្យប្តឹងតវ៉ារបស់ខ្លួន ។  សិស្សមានសិទ្ធិគ្រប់គ្រាន់ដើម្បីទាមទារនូវការវិនិច្ឆ័យដ៏សត្រឹមត្រូវ ដែលមានរួមបញ្ចូលទាំង ក) សំបុត្រលាយលក្ខអក្សរពន្យល់ពីបទបណ្តេញ, ខ) ពេលវេលាគ្រប់គ្រាន់ដើម្បីរៀបចំសំរាប់ការកាត់ក្តី, គ) សិទ្ធិគ្រប់គ្រាន់ក្នុងការតាំងតំណាងក្តីដោយមេធាវី ឬអ្នកជួយទាមទារសិទ្ធិឲ្យសិស្សណាផ្សេងទៀតដែលបង់លុយកាក់ដោយសិស្សផ្ទាល់, ឃ) មានសិទ្ធិបង្ហាញភស្តុតាងនិងសាក្សីផ្សេងៗ, ង)មានសិទ្ធិសាកសួរដល់សាក្សីដែលប្រឆាំងនឹងសិស្ស ហើយនិង ច)មានទទួលនូវការសំរេចចិត្តជាលាយលក្ខអក្សរក្នុងរយៈពេលដ៏ឆាប់ ស្តីពីបទចោទប្រកាន់សំរាប់ការកាត់សេចក្តីនោះ ។*

## **អាពាហ៍ពិពាហ៍, ដំណើរមានគភ៌, ភាពជាមាតាបិតា**
## **MARRIAGE, PREGNANCY, PARENTHOOD**

*យោងតាមច្បាប់ប្រតិបត្តិ ចែងនៅក្នុងច្បាប់រដ្ឋម៉ាស្សាឈូសែត* M.G.L.*មាត្រា* C.71 S.84 *គឺគ្មានសិស្សណាម្នាក់នឹងត្រូវបានគេបញ្ឈប់, បណ្តេញចេញ ឬដាក់ពិន័យពីបទពិរុទ្ធអ្វីឡើយ ដោយគ្រាន់តែមានករណីទាក់ទងទៅនឹងការរៀបការ, មាន*

*ផ្ទៃពោះ ឬក្លាយជាមាតាបិតាភាពនោះ ។ សិស្សទាំងឡាយណាដែលបានរៀបអាពាហ៍ពិពាហ៍, មានគភ៌ ឬបានក្លាយជាមាតាបិតា គឺនឹងបានទទួលស្មើៗគ្នានូវកម្មវិធីសិក្សារៀនសូត្រនៅសាលារៀន អ៊ិលម៉ាក់ ដែលមានរួមទាំងសកម្មភាពទាំងឡាយដែលទាក់ទងទាំអកម្មវិធីសិក្សាធម្មតា, កម្មវិធីក្រៅកិច្ចការសិក្សា និងកម្មវិធីទាំងឡាយផ្សេងទៀតផងដែរ ។*

*យោងតាមច្បាប់រដ្ឋសហព័ន្ធ មាត្រា* 603 CMR 23.00 *គឺថាពត៌មានទាំងឡាយដែលមាននៅក្នុង ឬបញ្ចូលទៅក្នុងបញ្ជីសំណុំរឿងសិក្សានៃសិស្ស គឺត្រូវមានកំណត់តែពត៌មានទាំងឡាយណាដែលទាក់ទងនៃការសិក្សារបស់សិស្សតែប៉ុណ្ណោះ ។*

*សាលារៀន ឆាទើ មិនត្រូវការតម្រូវឲ្យសិស្សដែលមានផ្ទៃពោះ បង្ហាញនូវលិខិតបញ្ជាក់ពីវេជ្ជបណ្ឌិត ដែលបញ្ជាក់ពីលទ្ធភាពនិងស្មារតីរឹងមាំក្នុងការបន្តការសិក្សារបស់ខ្លួននៅសាលារៀននោះឡើយ ។*

## ច្បាប់ទាក់ទងនឹងបញ្ជីសំណុំរឿងសិក្សាផ្សេងៗរបស់សិស្ស
## STUDENT RECORDS POLICY

*ដើម្បីនឹងផ្តល់ដល់សិស្សទាំងឡាយជាមួយនឹងការណែនាំឲ្យបានត្រឹមត្រូវ ហើយនិងសេវាកម្មសិក្សាផ្សេងៗនោះ វាមានការចាំបាច់ណាស់សម្រាប់សាលារៀន ម៉ីដល់ស៊ិក អាខាឌឹមី ឆាទើ ប្រចាំក្រុងឡូវែល ដើម្បីរក្សាពត៌មានផ្ទាល់ខ្លួនរបស់សិស្ស និងមាតាបិតារបស់គេទាំងអស់ឲ្យបានល្អហ្មត់ចត់ជាទីបំផុត ។ វាក៏ជាការចាំបាច់ណាស់ដែរ ដែលពត៌មាននៅក្នុងបញ្ជីសិក្សាទាំងឡាយនេះ នឹងត្រូវមានដោយងាយស្រួលផងដែរ សំរាប់បុគ្គលិកសាលាទាំងឡាយ រួមទាំងមានសំរាប់មាតាបិតារបស់សិស្ស ឬអ្នកអាណាព្យាបាល ឬក៏សំរាប់សិស្សដោយផ្ទាល់ យោងទៅតាមច្បាប់ប្រតិបត្តិ ហើយនឹងត្រូវស្ថិតនៅក្នុងការថែរក្សាដ៏ល្អត្រឹមត្រូវដោយរក្សាជាឯកសារសម្ងាត់បំផុតផងដែរ ។ នាយកសាលានឹងផ្តល់នូវការថែរក្សាពត៌មាននិងឯកសាររបស់សិស្សអោយបានសមស្របទៅតាមច្បាប់រដ្ឋ និងច្បាប់រដ្ឋាភិបាលសហព័ន្ធទាំងឡាយ ។*

*ច្បាប់រដ្ឋាភិបាលសហព័ន្ធតម្រូវឲ្យសាលារៀន ម៉ីដល់ស៊ិក អាខាឌឹមី ឆាទើ ប្រចាំក្រុងឡូវែល ផ្តល់ឈ្មោះ, អាស័យដ្ឋាន, និងលេខទូរស័ព្ទរបស់សិស្សវិទ្យាល័យទាំងឡាយ ទៅឲ្យក្រុមអ្នកកែនធ្វើទាហាន ហើយនិងស្ថាប័នសិក្សាផ្នែកឧត្តមសិក្សាទាំងឡាយដែលត្រូវការនូវពត៌មានទាំងឡាយនោះ ។ ក្នុងខណៈដែលសាលារៀនយើងព្យាយាមថែរក្សានូវឯកសារនៃសិស្សទាំងឡាយដោយហ្មត់ចត់បំផុត ប៉ុន្តែយើងក៏ត្រូវអនុវត្តន៍តាមច្បាប់ផងដែរ ។*

*បើមាតាបិតា ឬអ្នកអាណាព្យាបាលណាដែលមិនចង់ផ្តល់ឈ្មោះ និងពត៌មានសំរាប់ទាក់ទងរបស់កូនទៅក្រុមអ្នកកែនធ្វើទាហាន ឬស្ថាប័នឧត្តមសិក្សានោះទេ គឺត្រូវបំពេញ "ប័ណ្ណបដិសេធពុំព្រមចូលរួមនៃមាតាបិតា" ហើយត្រូវផ្ញើត្រលប់មកឲ្យសាលារៀនវិញជាកុំខានឡើយ ។ "ប័ណ្ណបដិសេធពុំព្រមចូលរួមនៃមាតាបិតា" នេះ គឺមានភ្ជាប់មកជាមួយនឹងស្រោមសំបុត្រដែលស្តីពីការទទួលយល់ព្រមរបស់សិស្សនោះ គឺត្រូវបានគេផ្ញើទៅឲ្យសិស្សនៅដើមឆ្នាំសិក្សានិមួយៗនោះហើយស្រាប់ ហើយយើងក៏មានឯកសារបន្ថែមទាំងឡាយនោះនៅឯការិយាល័យសាលារៀនផងដែរ ។ សូមកត់សំគាល់ថា គឺមាតាបិតាមានការជ្រើសរើសពត៌មានសិស្សពីក្រុមអ្នកកែនធ្វើទាហានថ្មី, ពីស្ថាប័នឧត្តមសិក្សាទាំងនោះផងដែរ ឬក៏អាចធ្វើទាំងពីរក៏បានដែរ ។ លើកលែងតែមាតាបិតា ឬអ្នកអាណាព្យាបាលផ្តល់ដំណឹងមកដល់សាលារៀនជាលាយលក្ខអក្សរ ដែលបញ្ជាក់មិនអនុញ្ញាតឲ្យ*

*បញ្ចេញនូវពត៌មានរបស់កូនសិស្ស នោះសាលារៀនត្រូវអនុវត្តន៍តាមច្បាប់ដោយបញ្ចេញឈ្មោះសិស្ស, អាស័យដ្ឋាន ហើយនិងលេខទូរស័ព្ទទៅឲ្យក្រុមអ្នកដើរកែនធ្វើទាហានថ្មី និងស្ថាប័នឧត្តមសិក្សាទាំងឡាយដែលបានស្នើសុំពត៌មានរបស់សិស្សទាំងឡាយរបស់សាលារៀនយើង ។*

*សូមមេត្តាជ្រាបជាដំណឹងថា "ប័ណ្ណបដិសេធពុំព្រមចូលរួមនៃមាតាបិតា" គឺអាចផ្ញើមកសាលារៀនបានគ្រប់ពេលវេលាទាំងអស់ នៅក្នុងខណៈដែលសិស្សមាននាទីសិក្សានៅសាលារៀនយើង ។ សូមមេត្តាផ្តល់យោបល់មកដល់នាយកសាលាជាលាយលក្ខអក្សរ បើសិនជាលោកអ្នកផ្លាស់ប្តូរការសំរេចចិត្តនៅពេលថ្ងៃក្រោយ ។*

*សិស្សណាម្នាក់ក៏អាចមានសិទ្ធិដាក់ពាក្យស្នើសុំមិនឲ្យពត៌មានរបស់ខ្លួនបញ្ចេញទៅក្រៅបានដែរ ។ មាតាបិតា ឬអ្នកអាណាព្យាបាលក៏ត្រូវបានគេជួយលើកទឹកចិត្តឲ្យនិយាយពិភាក្សាពីសំរេចចិត្តនេះជាមួយកូនសិស្សរបស់ខ្លួនឯងផងដែរ ។*

## សេចក្តីណែនាំពីសិទ្ធិទូទៅនៅក្រោម
## សិទ្ធិសិក្សាប្រចាំក្រុមគ្រួសារ និងច្បាប់ឯកជន (អក្សរកាត់ហៅថា ហ្វឺប៉ា)
## NOTIFICATION OF RIGHTS UNDER
## THE FAMILY EDUCATIONAL RIGHTS AND PRIVACY ACT (FERPA)

*សិទ្ធិសិក្សាប្រចាំក្រុមគ្រួសារ និងច្បាប់ឯកជន (អក្សរកាត់ហៅថា ហ្វឺប៉ា) គឺអាចប្រគល់សិទ្ធិដល់មាតាបិតា និងសិស្សាទាំងឡាយដែលមានអាយុលើសពី ១៨ឆ្នាំឡើងទៅ (សិស្សដែលចុះឈ្មោះចូលរៀន) នូវសិទ្ធិប្រភេទខ្លះៗ ដែលទាក់ទងទៅនឹងសំណុំរឿងសិក្សាផ្សេងៗរបស់សិស្ស ។ សិទ្ធិទាំងនេះ គឺមានដូចជា ៖*

(1) *សិទ្ធិអាចត្រួតពិនិត្យ និងពិនិត្យឡើងវិញនូវបញ្ជីសំណុំរឿងសិក្សារបស់សិស្សក្នុងរយៈពេល ៤៥ថ្ងៃ ពីថ្ងៃដែលសាលា បានទទួលសំណើរសំរាប់ការសុំចូលមើល ។ មាតាបិតា ឬសិស្សទាំងឡាយត្រូវដាក់ពាក្យស្នើជាលាយលក្ខអក្សរទៅកាន់នាយកសាលារៀន ម៉ីដល់ស៊ិក អាខាឌីម៉ី ឆាទើប្រចាំក្រុងឡូវែល (ឬអ្នកកាន់កិច្ចការសាលា) ដែលបញ្ជាក់ពីសំណុំរឿងណាមួយដែលខ្លួនចង់ត្រួតពិនិត្យមើល ។ អ្នកកាន់កិច្ចការសាលានឹងធ្វើការសំរួលសំរាប់ឲ្យមកមើលឯកសារ ហើយនិងប្រាប់ដំណឹងដល់មាតាបិតា ឬសិស្សពីពេលវេលានិងទីកន្លែងដែលនឹងអាចមកមើលឯកសារទាំងនោះបានផងដែរ ។*

(2) *សិទ្ធិអាចស្នើសុំការកែប្រែនូវសំណុំរឿងសិក្សារបស់ខ្លួន ដែលមាតាបិតាឬសិស្សមានជំនឿថាមិនត្រឹមត្រូវ ។ មាតាបិតា ឬសិស្សទាំងឡាយអាចសាកសួរសាលារៀន ដើម្បីកែប្រែនូវបញ្ជីសំណុំរឿងសិក្សាដែលពួកគេយល់ថាមិនមានការត្រឹមត្រូវ ។ ពួកគេគួរសរសេរទៅកាន់នាយកសាលារៀន ម៉ីដល់ស៊ិក អាខាឌីម៉ី ឆាទើ ប្រចាំក្រុងឡូវែល (ឬអ្នកទទួលបន្ទុកសាលាណាម្នាក់) ហើយបញ្ជាក់ឲ្យបានច្បាស់លាស់ពីផ្នែកណាមួយនៃសំណុំរឿងដែលខ្លួនចង់ផ្លាស់ប្តូរ និងបញ្ជាក់មូលហេតុដែលពត៌មានមិនត្រឹមត្រូវទាំងនោះផងដែរ ។ បើសិនសាលាសំរេចចិត្តថាមិនកែប្រែនូវសំណុំរឿងសិក្សាដូចដែលបានស្នើសុំដោយមាតាបិតាឬសិស្សនោះទេ សាលានឹងប្រាប់ដល់មាតាបិតាឬសិស្សពីការសំរេចចិត្ត ហើយនិងផ្តល់នូវឱវាទដល់ពួកគេពីសិទ្ធិរបស់គេក្នុងការដាក់ពាក្យទាមទារតវ៉ាសំរាប់ការផ្លាស់ប្តូរនោះ ។ ពត៌មានបន្ថែមទាក់ទងនឹងនីតិវិធីសុំតវ៉ា នឹងត្រូវផ្តល់ដល់មាតាបិតាឬសិស្សពីពេលវេលានៃសិទ្ធិដើម្បីការឡើងតវ៉ានោះ ។*

(3) *សិទ្ធិអាចយល់ព្រមទៅនឹងការលាតត្រដាងប្រាប់ពីពត៌មានរបស់ខ្លួនដែលនៅក្នុងបញ្ជីរសំណុំឯកសារសិក្សារបស់សិស្ស ទាំងឡាយ, លើកលែងតែអនុញ្ញាតឲ្យធ្វើទៅបានតាមច្បាប់ ហ្វឺប៉ា ដែលអាចបញ្ចេញទៅបានដោយគ្មានការយល់ព្រម ។*

*មានការលើកលែងមួយ ដែលអនុញ្ញាតឲ្យការលាតត្រដាងដែលមិនចាំបាច់ត្រូវការយល់ព្រម គឺការលាតត្រដាងប្រាប់ទៅក្រុមអភិបាលសាលារៀនដែលមានការចាប់អារម្មណ៍ដ៏ពិតប្រាកដពីបញ្ហាសិក្សា ។ អភិបាលសាលារៀន គឺជាបុគ្គលម្នាក់ដែលត្រូវបានគេជួលដោយសាលា ជាអភិបាលគ្រប់គ្រង, អ្នកត្រួតត្រា, គ្រូបង្រៀន, ឬជាសមាជិកបុគ្គលិកជំនួយ (រួមបញ្ចូលទាំងបុគ្គលិកផ្នែកសុខភាព ឬខាងពេទ្យ និងខាងផ្នែកសន្តិសុខផងដែរ), អ្នកដែលចូលបំរើជាគណៈកម្មការក្រុមប្រឹក្សាសាលារៀន, មនុស្ស ឬក្រុមហ៊ុនដែលសាលារៀនមានទំនាក់ទំនងជាមួយ ដើម្បីធ្វើកិច្ចការពិសេសអ្វីមួយ (ដូចជាមេធាវី, អ្នកត្រួតពិនិត្យបញ្ជីថវិកា, អ្នកឯកទេសខាងពេទ្យ, ឬពេទ្យចាប់សរសៃ) ឬក៏មាតាបិតា ឬក៏សិស្សណាម្នាក់ដែលស្ម័គ្រចិត្តចូលបំរើកិច្ចការក្នុងគណៈកម្មការណាមួយ ដូចជាគណៈកម្មការខាងផ្នែកវិន័យ ឬបទបណ្តឹងសាទុក្ខ* (Grievance), *ឬផ្តល់ជំនួយដល់អភិបាលសាលាក្នុងការបំពេញកិច្ចការនានាជាដើម ។*

*អភិបាលសាលារៀនមានចំណាប់អារម្មណ៍ដ៏ត្រឹមត្រូវ បើសិនជាអភិបាលនោះត្រូវការពិនិត្យមើលនូវសំណុំឯកសារសិក្សា ក្នុងគោលបំណងចង់បំពេញករណីយកិច្ចរបស់ខ្លួន ។*

(4) *សិទ្ធិអាចបំពេញបទបណ្តឹងជាមួយនឹងក្រសួងសិក្សារដ្ឋាភិបាលសហព័ន្ធ ទាក់ទងនឹងការខ្វះខាត ឬការធ្វេសប្រហែសនៃក្រសួងសិក្សាប្រចាំតំបន់ នៅក្នុងការបំពេញភារកិច្ចនៃសេចក្តីត្រូវការទាំងឡាយនៃច្បាប់ ហ្វឺប៉ា ។ ឈ្មោះនិងអាស័យដ្ឋាននៃការិយាល័យដែលទទួលបន្ទុកចាត់ចែងខាងច្បាប់ ហ្វឺប៉ា មានដូចខាងក្រោមនេះ ៖*

Family Policy Compliance Office
U.S. Department of Education
400 Maryland Avenue, SW
Washington, DC 20202-5901

# សេចក្តីណែនាំពីសិទ្ធិទូទៅនៅក្រោម ការកែប្រែសិទ្ធិការពារទាំងឡាយរបស់សិស្ស ( អក្សរកាត់ហៅថា ភីប្រា )

# NOTIFICATION OF RIGHTS UNDER THE PROTECTION OF PUPIL RIGHTS AMENDMENT (PPRA)

*ច្បាប់ភីប្រាអាចផ្តល់សិទ្ធិនានាដល់មាតាបិតាទាក់ទងដល់ការធ្វើស្រង់ស្ទង់មតិមហាជន, ការប្រមូលនិងការប្រើប្រាស់នៃពត៌មានសំរាប់គោលបំណងស្វែងយល់ពីទីផ្សារនានា ហើយនិងការពិនិត្យមើលសពាង្គកាយផ្សេងៗ ។ សិទ្ធិទាំងនេះ គឺមានដូចតទៅ ៖*

• **ការយល់ព្រម** *មុននឹងសិស្សទាំងឡាយតម្រូវឲ្យដាក់សុំធ្វើមតិដែលទាក់ទងនូវផ្នែកណាមួយឬច្រើនជាង ដែលស្ថិតនៅក្រោមការការពារ (ការស្ទង់មតិពត៌មានដែលគេការពារ) បើសិនជាការស្ទង់មតិនោះបានទទួលការឧបត្ថម្ភទាំងស្រុងឬជាផ្នែកណាមួយនៃកម្មវិធីរបស់ក្រសួងសិក្សារដ្ឋាភិបាលសហព័ន្ធ –*

1. *អង្គការនយោបាយនានា ឬជំនឿផ្សេងៗរបស់សិស្ស ឬមាតាបិតានៃសិស្ស ;*
2. *បញ្ហាផ្សេងៗទាក់ទងខាងបញ្ញា ឬខាងចិត្តសាស្ត្រនៃសិស្ស ឬគ្រួសាររបស់សិស្ស;*

3. *ចរិយាផ្លូវភេទ ឬអាកប្បកិរិយាទាំងឡាយ;*
4. *ចរិតដែលល្មើសច្បាប់, ប្រឆាំងសង្គម, ចោទទោសលើខ្លួនឯង ឬចរិកថោកទាបអ្វីមួយ;*
5. *ការវាយតម្លៃរិះគន់អ្នកដទៃដែលអ្នកឆ្លើយសំណួរមានជាប់សាច់សារលោហិតជាមួយ;*
6. *ទំនាក់ទំនងផ្សេងៗស្របតាមច្បាប់ដែលមានលក្ខណៈពិសេស, ដូចជា ជាមួយមេធាវី, វេជ្ជបណ្ឌិត ឬរដ្ឋមន្ត្រីទាំងឡាយ;*
7. *ការអនុវត្តន៍សាសនា, សមាគម ឬជំនឿផ្សេងៗរបស់សិស្ស ឬមាតាបិតាសិស្ស; ឬក៏*
8. *ប្រាក់ចំណូល, អ្វីផ្សេងទៀតដែលតម្រូវដោយច្បាប់ដើម្បីពិនិត្យវិនិច្ឆ័យពីភាពអាចចូលរួមក្នុងកម្មវិធីណាមួយ ។*

- **ការទទួលលិខិត ហើយនិងឱកាសដើម្បីជ្រើសសិស្សមិនចង់ឲ្យចូលរួម** –
    1. *ការស្ទង់មតិយកពត៌មានអ្វីផ្សេងៗ, មិនថាប្រភពជំនួយនោះមកពីណាក៏ដោយ;*
    2. *ការពិនិត្យមើលសាពាង្គកាយអ្វីមួយដែលមិនរាតត្បាត តែមិនមានភាពអាសន្ន ឬការឆ្លុះមើលដែលតម្រូវការជាលក្ខខណ្ឌនៃការចូលរៀន, ដែលចាត់ចែងឡើយដោយសាលារៀន ឬភ្នាក់ងាររបស់សាលារៀន ហើយដែលមិនចាំបាច់ត្រូវការពារដល់សុខភាពភ្លាមៗ និងពីសុវត្ថិភាពរបស់សិស្ស, វៀរលែងណាតែសំរាប់ការពិនិត្យសោតវិញ្ញាណ (ស្តាប់), ចក្ខុវិញ្ញាណ (ភ្នែក) ឬអាការៈវៀចឆ្អឹងខ្នង ឬការពិនិត្យរាងកាយឬការឆ្លុះពិនិត្យមើលដែលអនុញ្ញាតឲ្យ ឬតម្រូវដោយច្បាប់រដ្ឋ; ហើយនិង*
    3. *សកម្មភាពផ្សេងៗដែលទាក់ទងនឹងការប្រមូល, ការលាតត្រដាង, ឬការប្រើប្រាស់នៃពត៌មានផ្ទាល់ខ្លួន ដែលបានមកពីសិស្សទាំងឡាយសំរាប់ការស្វែងយល់ពីទីផ្សារ ឬដើម្បីលក់ ឬដើម្បីចែកចាយពត៌មានទៅឲ្យអ្នកដទៃទៀត ។*

- **ត្រួតពិនិត្យ**, *បន្ទាប់ពីការស្នើសុំ និងនៅមុនការគ្រប់គ្រង ឬការប្រើប្រាស់* –
    1. *ពត៌មានស្ទង់មតិដែលការពារសិស្ស;*
    2. *ឧបករណ៍ប្រើប្រាស់ដើម្បីប្រមូលពត៌មានផ្ទាល់ខ្លួនពីសិស្សទាំងឡាយសំរាប់ការស្វែងយល់ពីទីផ្សារដូចបានរៀបរាប់ខាងលើ, ការលក់ដូរ ឬក្នុងគោលបំណងចែកចាយអ្វីផ្សេងៗទៀត; ហើយនិង*
    3. *សម្ភារៈបង្រៀនផ្សេងៗដែលប្រើប្រាស់ជាផ្នែកអ្វីមួយនៃកម្មវិធីសិក្សា ។*

*សិទ្ធិទាំងឡាយនេះអាចផ្លាស់ប្តូរពីមាតាបិតាទៅសិស្សដែលមានអាយុ ១៨ឆ្នាំ ឬក្មេងដែលមានសិទ្ធិសេរីដោយខ្លួនឯងដែលចែងឡើងដោយច្បាប់រដ្ឋ ។*

*សាលារៀន* មីដល់សិក អាខាឌីមី ឆាទើ ប្រចាំក្រុងឡូវែល *នឹងបង្កើត ហើយនឹងអនុវត្តន៍ច្បាប់នានា, រួមទាំងការពិភាក្សាជាមួយមាតាបិតា, ទាក់ទងនឹងសិទ្ធិទាំងនេះ ហើយនិងការរៀបចំផ្សេងៗ ដើម្បីការពារនូវការសម្ងាត់របស់សិស្សនៅក្នុងការគ្រប់គ្រងមតិពត៌មានទាំងឡាយនិងការប្រមូល, ការលាតត្រដាង ឬការប្រើប្រាស់នូវពត៌មានផ្ទាល់ខ្លួនសំរាប់ទីផ្សារ, លក់ដូរ ឬគោលការចែកចាយដទៃៗទៀត ។*

*សាលារៀន* មីដល់សិក អាខាឌីមី ឆាទើ ប្រចាំក្រុងឡូវែល *នឹងផ្តល់ដំណឹងដល់មាតាបិតាអំពីច្បាប់ទាំងឡាយនេះ យ៉ាងហោចណាស់ឲ្យបានជាប្រចាំឆ្នាំ គឺនៅមុនចាប់ផ្តើមឆ្នាំសិក្សា និងបន្ទាប់ពីការផ្លាស់ប្តូរអ្វីផ្សេងៗ ។ សាលា* មីដល់សិក អាខាឌីមី ឆាទើ ប្រចាំក្រុងឡូវែល *នឹងជំរាបប្រាប់ដោយផ្ទាល់ផងដែរ ដូចជាតាមរយៈផ្ញើសំបុត្រប្រៃណីយ៍សហរដ្ឋ ឬតាមអ៊ីម៉ែល ដល់មាតាបិតានៃសិស្សទាំងឡាយដែលត្រូវបានដាក់កាលបរិច្ឆេទឲ្យមកជួប ហើយនិងចូលរួមនៅក្នុងសកម្មភាពនិងការស្ទង់មតិផ្សេងៗ ដូចបានអធិប្បាយនៅខាងក្រោម ហើយនឹងផ្តល់នូវឱកាសសំរាប់ជ្រើសរើសដកកូនរបស់ខ្លួនចេញពីការចូលរួមនៅក្នុងសកម្មភាព ឬការស្ទង់មតិអ្វីមួយផងដែរ ។ សាលា* មីដល់សិក អាខាឌីមី ឆាទើ ប្រចាំក្រុងឡូវែល *នឹងធ្វើការផ្តល់ដំណឹងនេះទៅដល់មាតាបិតានៅពេលមុនដំបូងនៃឆ្នាំសិក្សា បើសិនជាក្រសួងសិក្សាប្រចាំតំបន់បានផ្តល់បង្ហាញពេលវេលា ឬថ្ងៃខែដ៏សមរម្យណាមួយនៃគំរោងសកម្មភាព ឬការស្ទង់មតិនានា នៅពេលដែលបាន*

*កំណត់រួចហើយនោះ ។ សំរាប់គម្រោងស្ទង់មតិ និងសកម្មភាពទាំងឡាយដែលបានកំណត់ទុក បន្ទាប់ពីឆ្នាំសិក្សាចាប់ផ្តើម, មាតាបិតានឹងផ្តល់ដំណឹងដ៏សមរម្យនៃសកម្មភាពដែលបានគ្រោងទុកនានា ហើយនិងការស្ទង់មតិផ្សេងៗ ដូចបានចុះបញ្ជីបញ្ជាក់ខាងក្រោម ហើយក៏នឹងផ្តល់ឧកាសដើម្បីជ្រើសរើសមិនឲ្យកូនចូលរួមនៅក្នុងសកម្មភាពនិងការស្ទង់មតិទាំងឡាយនោះផងដែរ ។ មាតាបិតានឹងត្រូវបានគេផ្តល់ឧកាស ដើម្បីពិនិត្យមើលសារឡើងវិញនូវការស្ទង់មតិផ្សេងៗដែលទាក់ទងនឹងកូនចៅរបស់ខ្លួនផងដែរ ។*

*ខាងក្រោមនេះ គឺជាបញ្ជីរៀបរាប់ពីសកម្មភាពនិងការស្ទង់មតិនានាដែលបានរួមបញ្ចូលនៅក្រោមសេចក្តីតម្រូវការនេះ ៖*

- *ការប្រមូល, ការលាតត្រដាង ឬការប្រើប្រាស់នៃពត៌មានផ្ទាល់ខ្លួនសំរាប់ការស្វែងយល់ពីទីផ្សារ, ការលក់ដូរ ឬការចែកចាយពត៌មានផ្សេងៗ ។*
- *ការគ្រប់គ្រងនៃពត៌មានស្ទង់មតិដែលត្រូវគេរក្សាការពារ ដែលមិនត្រូវបានឧកត្ថម្ភទាំងស្រុងឬជាផ្នែកដោយក្រសួងសិក្សារដ្ឋាភិបាលសហព័ន្ធ ។*
- *ការពិនិត្យដែលរាតត្បាត តែមិនមែនជាបញ្ហាអាសន្ន ឬការឆ្មុះពិនិត្យដូចបានអធិប្បាយនៅខាងលើស្រេច ។*

**មាតាបិតាទាំងឡាយដែលមានជំនឿថាសិទ្ធិរបស់ខ្លួនត្រូវបានគេរំលោភលើ អាចប្តឹងតវ៉ាជាមួយនឹងក្រសួងដូចខាងក្រោម ៖**

Family Policy Compliance Office
U.S. Department of Education
400 Maryland Avenue, SW
Washington, D.C.  20202-5920

## ការឆែកឆេរ និង ការរឹបអូសយក
## SEARCH AND SEIZURE

*សិស្សទាំងអស់ដែលចុះឈ្មោះចូលរៀននៅក្នុងសាលា មីដល់ស៊ិក អាខាឌឺមី ឆាទើ ប្រចាំក្រុងឡូវែល នឹងមានសេរីភាពគេចផុតពីការឆែកឆេរតាមទំនើងចិត្តទៅលើខ្លួនប្រាណ, ទ្រព្យសម្បត្តិរបស់ខ្លួន ឬទ្រព្យសម្បត្តិសាលាដែលបានផ្តល់ដល់ខ្លួន ហើយនិងការរឹបអូសយកនូវទ្រព្យសម្បត្តិទាំងឡាយនោះផងដែរ ។*

*គឺត្រូវមានមូលហេតុដ៏សមរម្យណាមួយសំរាប់បុគ្គលិកសាលារៀន ដើម្បីធ្វើរការឆែកឆេរខ្លួនប្រាណសិស្ស, ទ្រព្យសម្បត្តិរបស់សិស្ស ឬទ្រព្យសម្បត្តិសាលាដែលបានប្រគល់ឲ្យសិស្សប្រើ ។ សាលារៀននឹងធ្វើការឆែកឆេរទូទៅទាំងឡាយនៃសាលា និងទ្រព្យសម្បត្តិសាលា បើសិនជាមានមូលហេតុដ៏សមរម្យណាមួយដែលបណ្តាលឲ្យធ្វើការឆែកឆេរនោះ ។*

*ការឆែកឆេរទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់សិស្ស ឬទ្រព្យសម្បត្តិសាលាដែលប្រគល់ឲ្យសិស្សប្រើ នឹងត្រូវធ្វើឡើងនៅក្នុងវត្តមានរបស់សិស្ស, លើកលែងតែនៅក្នុងករណីអាសន្នដែលមានភាពគ្រោះថ្នាក់អ្វីមួយអាចកើតឡើងដល់សុវត្ថិភាព ឬសន្តិសុខនៃសាលារៀន ឬមនុស្សណាម្នាក់នៅក្នុងសាលារៀន។ បន្ទាប់មក សិស្សនឹងត្រូវគេផ្តល់ដំណឹងឲ្យដឹងបានយ៉ាងឆាប់រហ័ស ។*

*វត្ថុផ្សេងៗដែលល្មើសនឹងច្បាប់មានរួមបញ្ចូលទាំងសាស្ត្រាវុធ, វត្ថុជាតុហាមឃាត់, គ្រាប់ ឬរំសេវផ្ទុះទាំងឡាយ ហើយនិងវត្ថុដទៃដែលត្រូវបានចាត់ទុកថា អាចបណ្តាលមានអសន្តិសុខ ឬអសុវត្ថិភាពដល់សាលារៀន ឬមនុស្សទាំងឡាយដែលនៅក្នុងសាលារៀន គឺនឹងត្រូវគេរឹបអូសយកចេញដោយបុគ្គលិកសាលា ។*

*បើសិនការឆែកឆេរដែលផ្តល់នូវវត្ថុឬសកម្មភាពផ្សេងៗ ដែលល្មើសនឹងច្បាប់រដ្ឋ, ក្រសួងនគរបាលនៃទីក្រុងឡូវែល នឹងត្រូវបានគេផ្តល់ដំណឹងប្រាប់ភ្លាមៗ ផងដែរ ។*

## សេចក្តីបញ្ជាក់ប្រឆាំងនឹងអំពើសម្លុតធ្វើបាប
## ANTI-HAZING AFFIRMATION

*សាលារៀនអ៊ិលម៉ាក់ ហាមឃាត់ដ៏តឹងរឹងចំពោះទង្វើគ្រប់ប្រភេទនៃអំពើសម្លុតធ្វើបាបអ្វីមួយក្នុងចំណោមសិស្សទាំងឡាយនៅក្នុងក្រុមសិស្ស, ពួកសិស្ស ហើយនិងអង្គការទាំងឡាយ ។ យោងតាមច្បាប់ទូទៅនៃរដ្ឋម៉ាស្សាឈូសែ, សាលា អ៊ិលម៉ាក់ សូមធ្វើការប្រកាសប្រាប់ជាលាយលក្ខអក្សរស្តីពីច្បាប់ប្រតិបត្តិដល់សិស្សទាំងអស់ ហើយនិងតម្រូវឲ្យសិស្ស និងបុគ្គលិកទាំងអស់រាយការណ៍ដល់នាយកប្រតិបត្តិសាលាជាបន្ទាន់ ពីអំពើនានាដែលទាក់ទងនឹងការសម្លុតធ្វើបាប ។ វាគឺជាករណីយកិច្ចរបស់នាយកប្រតិបត្តិសាលា ដើម្បីស៊ើបអង្កេតនិងអនុវត្តន៍នូវសកម្មភាពដ៏សមរម្យណាមួយ, រួមទាំង, តែមិនមានកំណត់តែការ ព្រមាន, ការបញ្ឈប់ពីសាលាឬពីការងារ, ការបណ្តេញចេញពីសាលាឬការបញ្ចប់ពីការងារនោះឡើយ ។ បើសិនជាមានកស្តុតាងច្រើនលើសលប់ នាយកសាលានឹងចេញជាលាយលក្ខអក្សររបាយការណ៍ទៅកាន់ក្រុមប្រឹក្សាសាលាក្នុងរយៈពេល ១៤ថ្ងៃបន្ទាប់ពីថ្ងៃដែលកើតមានហេតុការណ៍នោះឡើង ។ ការស៊ើបអង្កេតដ៏ហ្មត់ចត់ ក៏នឹងអនុវត្តិដែរ ដើម្បីធ្វើឲ្យមានតម្លាភាព ហើយនិងរក្សាសិទ្ធិនៃក្រុមអ្នកទាំងឡាយដែលបានទាក់ទងក្នុងរឿងនោះ ។*

## ច្បាប់ប្រតិបត្តិទូទៅនៃរដ្ឋម៉ាស្សាឈូសែត មាត្រាទី ២៦៩ ស្តីពីបទឧក្រិដ្ឋប្រឆាំងនឹងសន្តិភាពសាធារណៈ
## MASSACHUSETTS GENERAL LAWS CHAPTER 269 CRIMES AGAINST PUBLIC PEACE

### មាត្រាទី ២៦៩, ជំពូក S.១៧ ស្តីពីបទឧក្រិដ្ឋនៃអំពើសម្លុតបុការធ្វើបាប, និយមន័យ; ទោសបញ្ញត្តិ
<u>CH. 269, S.17. CRIME OF HAZING, DEFINITION; PENALTY</u>

*ជនណាក៏ដោយ ដែលជាមេបញ្ជារៀបចំឬជាអ្នកចូលរួមនៅក្នុងឧក្រិដ្ឋកម្មនៃអំពើសម្លុតធ្វើបាបគេ ដូចដែលបានចែងក្នុងនិយមន័យនៅទីនេះ, នឹងត្រូវបានគេដាក់ទណ្ឌកម្មដោយការបង់ប្រាក់ពិន័យដែលមិនច្រើនជាងបីពាន់ដុល្លា ឬដោយការជាប់គុកនៅក្នុងពន្ធនាគារសំរាប់កសាងអប់រំក្នុងកំណត់មិនច្រើនជាងមួយឆ្នាំ ឬត្រូវទទួលទោសទាំងទ្វេ គឺត្រូវបង់ប្រាក់ពិន័យផង និងត្រូវជាប់គុកផងដែរ ។*

*ពាក្យថា "**ការសម្លុត ឬការធ្វើបាប**" ដូចដែលបានប្រើនៅក្នុងជំពូកនេះ ហើយនិងនៅក្នុងជំពូកទីដប់ប្រាំបី និងដប់ប្រាំបួន នឹងមាននិយមន័យថា អំពើរ ឬវិធីសាស្រ្តនៃការនាំបញ្ចូលទៅក្នុងក្រុម ឬអង្គការសិស្សណាមួយ ទោះប្រព្រឹត្តទៅនៅលើបរិវេណសាធារណៈ ឬឯកជនក្តី ដែលធ្វើឲ្យមានគ្រោះថ្នាក់ដោយចេតនា ឬដោយឥតបើគិតក្តី ដល់រូបរាងកាយ ឬសតិអារម្មណ៍នៃសិស្សណាម្នាក់ ឬដល់មនុស្សដទៃទៀត ។ អំពើរនេះ ដែលមានរួមបញ្ចូលទាំងការវាយដោយខ្សែតីយ, ការវាយធ្វើទារុណកម្ម, ការសង្កត់ឲ្យកើតជាស្នាម, ការហាត់ប្រាណដោយបង្ខំ, ការដាក់ឲ្យត្រូវអាកាសធាតុ, ការបង្ខំឲ្យបរិភោគអាហារ, ផឹកគ្រឿងស្រវឹង, វេសជ្ជៈ, ការបង្ខំឲ្យលេបថ្នាំ ឬវត្ថុធាតុ ឬការធ្វើបាប ឬបង្ខំឲ្យធ្វើសកម្មភាពអ្វីដែលបណ្តាលឲ្យមានបញ្ហាដល់សុខភាព ឬប៉ះពាល់ដល់សន្តិសុខនៃសិស្សណាម្នាក់ ឬមនុស្សដទៃទៀត ឬដែលធ្វើឲ្យសិស្ស ឬអ្នកដទៃទៀតទទួលទារុណកម្ម ដោយផ្លូវចិត្ត ឬដោយមនោសញ្ចេតនាអ្វីមួយក្តី មានរួមបញ្ចូលទាំងការបង្ខំមិនឲ្យដេកអស់រយៈពេលជាច្រើនថ្ងៃ ឬការឈប់សំរាក ឬការឃុំឃាំងនៅកន្លែងដាច់ស្រយាល ។*

*ម៉្យាងទៀត ទោះបីមានការកែប្រែផ្សេងៗនៃជំពូកនេះ ដែលមានការផ្ទុយគ្នាក៏ដោយ ក៏ការព្រមព្រៀងនឹងមិនមានសិទ្ធិសំរាប់ធ្វើជាការប្រឆាំងតវ៉ាទៅនឹងភាគីដើមចោទណាមួយនៅក្រោមចលនានេះឡើយ ។ ច្បាប់នេះបានបន្ថែមឡើងដោយជំពូក* St. 1985, *មាត្រាទី* c.536; *បានកែប្រែសម្រួលឡើងដោយជំពូក* St.1987 *មាត្រាទី* c.665 ។

## មាត្រាទី ២៦៩, ជំពូក S. ១៨ ស្តីពីការណើយកិច្ចដើម្បីរាយការណ៍ពីអំពើសម្លុតឬការធ្វើបាប
<u>CH. 269, S.18. DUTY TO REPORT HAZING</u>

*ជនណាក៏ដោយ ដែលបានដឹងឮថាមនុស្សម្នាក់ដទៃទៀតជាជនរងគ្រោះនៃអំពើសម្លុតធ្វើបាប ដូចដែលបានឲ្យនិយមន័យនៅក្នុងជំពូកដប់ប្រាំពីរ ហើយនិងនៅនឹងកន្លែងដែលកើតហេតុឧក្រិដ្ឋនោះ នឹងត្រូវ, តាមតែអាចធ្វើទៅបានដោយគ្មានភាពគ្រោះថ្នាក់ ឬហានិភ័យដល់ខ្លួនឯងឬអ្នកដទៃ, រាយការណ៍ពីបទឧក្រិដ្ឋកម្មទៅមន្រ្តីច្បាប់ណាដែលត្រឹមត្រូវសមរម្យឲ្យបានឆាប់រហ័សដែលអាចធ្វើទៅបានដូចការចែងច្បាប់ធរមាន ។ ជនណាដែលអាកខានរាយការណ៍ពីបទឧក្រិដ្ឋនេះ នឹងត្រូវទទួលទោសដោយបង់ប្រាក់ពិន័យ ដែលមិនច្រើនជាងមួយពាន់ដុល្លា ។ ច្បាប់បានបន្ថែមឡើងដោយជំពូក* St.1985, *មាត្រាទី* c.536; *បានកែប្រែឡើយដោយជំពូក* St.1987, *មាត្រាទី* c.665 ។

## មាត្រាទី ២៦៩, ជំពូក S. ១៩ ស្តីពីវបញ្ញាត្តិនៃពីអំពើសម្លុតឬការធ្វើចាប; សេចក្តីថ្លែងការណ៍នៃការអនុលោមតាម និង ច្បាប់វិន័យដែលតម្រូវអោយប្រតិបត្តិតាម
<u>CH. 269 S.19. HAZING STATUTES TO BE PROVIDED; STATEMENT OF COMPLIANCE AND DISCIPLINE POLICY REQUIRED</u>

*ស្ថាប័ននិមួយៗនៃសាលាវិទ្យាល័យ ហើយនិងស្ថាប័នសាធារណៈនិងឯកជននៃសាលាឧត្តមសិក្សា នឹងចេញផ្សព្វផ្សាយដល់ក្រុមនិស្សិតនិមួយៗ, ពួកនិស្សិត ឬសមាគមនិស្សិតណាមួយដែលជាសាខានៃស្ថាប័ន ឬដែលបានទទួលស្គាល់ដោយស្ថាប័ននេះ ឬដែលបានអនុញ្ញាតដោយស្ថាប័នដើម្បីប្រើប្រាស់ឈ្មោះស្ថាប័នរបស់ខ្លួន ឬប្រើប្រាស់បរិវេណស្ថាប័ន ឬការទទួលស្គាល់ថាមិនមែនជាក្រុមនិស្សិត, ពួកនិស្សិត ឬសមាគមនិស្សិត, ក្រដាសច្បាប់ជំពូកនេះ និងជំពូកទីដប់ប្រាំមួយនិងដប់ប្រាំពីរ ។ បើដរាបណា, ទោះបីយ៉ាងណាក៏ដោយ, ការប្រព្រឹត្តតាមរបស់ស្ថាប័នជាមួយនឹងតម្រូវការជំពូកនេះ ដែលស្ថាប័នបានចេញក្រ*

*ជាសប្រកាសផ្សព្វផ្សាយនានាពីជំពូកនេះ ហើយនិងជំពូកដប់ប្រាំពីរ និងដប់ប្រាំបីទៅដល់ក្រុមនិស្សិតដែលមិនមានខ្សែរយៈទាក់ទងនឹងសាលាទាំងនោះ, ក្រុមឬសមាគមទាំងឡាយ នោះមានន័យថាក្រុមទាំងនោះនឹងមិនមានកស្តុតាងអ្វីដែលទាក់ទងនឹងការទទួលស្គាល់របស់ស្ថាប័នសាលារៀន ឬទទួលការគាំទ្រពីក្រុមនិស្សិត, ពួកនិស្សិត ឬសមាគមនិស្សិតទាំងនោះឡើយ ។*

*ក្រុម, ពួក ឬសមាគមនិមួយៗ នឹងត្រូវបានគេចែកចាយអោយនូវក្រដាស់ច្បាប់ជំពូកនេះ ហើយនិងជំពូកទីដប់ប្រាំពីរ និងដប់ប្រាំបីទៅដល់សមាជិកក្រុមនិស្សិត, សិស្សហ្វឹកហាត់ទាហានថ្មី ឬអ្នកដាក់សុំពាក្យចូលជាសមាជិកថ្មីទាំងឡាយផងដែរ ។ វាគឺជាករណីយកិច្ចនៃក្រុម, ពួក ឬសមាគមនិស្សិតនិមួយៗ តាមរយៈមេឬប្រធានក្រុម ដើម្បីចែកចាយជារៀងរាល់ឆ្នាំទៅឲ្យស្ថាប័ននូវលិខិតបញ្ជាក់ថាបានទទួលដឹងឮដំពិតប្រាកដ ដែលសបញ្ជាក់ថាក្រុម, ពួក ឬសមាគមនិស្សិតនិមួយៗបានទទួលក្រដាសស្នាមនៃច្បាប់ជំពូកនេះ ហើយនិងជំពូកទីដប់ប្រាំពីរនិងដប់ប្រាំបី និងសមាជិកទាំងអស់នៃក្រុម, ពួក ឬសមាគមនិស្សិតនិមួយៗ បានទទួលយល់ព្រមនឹងអនុវត្តន៍តាមជាមួយនឹងវគ្គនានានៃច្បាប់នៅក្នុងជំពូកនេះ ហើយនិងជំពូកទីដប់ប្រាំពីរ និងដប់ប្រាំបីផងដែរ ។*

*ស្ថាប័ននិមួយៗនៃសាលាវិទ្យាល័យ ហើយនិងស្ថាប័នសាធារណៈ ឬឯកជននៃសាលាឧត្តមសិក្សានិមួយៗ នឹងត្រូវ, យ៉ាងហោចណាស់អោយបានជារៀងរាល់ឆ្នាំ ជាពិសេសនៅមុនឬនៅពេលចុះឈ្មោះចូលរៀន, ផ្តល់ដល់សិស្សទាំងឡាយណាដែលចុះឈ្មោះចូលរៀនពេញពេលវេលានៅក្នុងស្ថាប័នសិក្សាណាមួយក៏ដោយ នូវក្រដាសច្បាប់ដែលចែងនៅក្នុងជំពូកនេះ ហើយនិងនៅក្នុងជំពូកទីដប់ប្រាំពីរនិងដប់ប្រាំបីផងដែរ ។*

*ស្ថាប័ននិមួយៗនៃសាលាវិទ្យាល័យ ហើយនិងស្ថាប័នសាធារណៈ ឬឯកជននៃសាលាឧត្តមសិក្សានិមួយៗ នឹងត្រូវ, យ៉ាងហោចណាស់អោយបានជារៀងរាល់ឆ្នាំ, បំពេញរបាយការណ៍ជាមួយនឹងប្រឹក្សាភិបាលទាំងឡាយនៃសាលាឧត្តមសិក្សា ហើយនៅក្នុងករណីនៃសាលាវិទ្យាល័យទាំងឡាយវិញ គឺត្រូវបំពេញរបាយការណ៍ជាមួយនឹងក្រុមប្រឹក្សាសាលា, ដើម្បីបញ្ជាក់ថាស្ថាប័ននោះបានធ្វើប្រតិបត្តិតាមជាមួយនឹងករណីយកិច្ចរបស់ខ្លួនហើយក្នុងការប្រាប់ដល់ក្រុមនិស្សិត, ពួកនិស្សិត ឬសមាគមនិស្សិតទាំងឡាយនោះ ហើយនិងប្រាប់ដល់សិស្សដែលចុះឈ្មោះចូលរៀនពេញម៉ោងទាំងអស់នូវក្រដាសច្បាប់ផ្សេងៗដែលបានចែងនៅក្នុងជំពូកនេះ ហើយនិងនៅក្នុងជំពូកទីដប់ប្រាំពីរនិងដប់ប្រាំបី ហើយក៏ត្រូវបញ្ជាក់បន្ថែមផងដែរថាស្ថាប័ននោះបានអនុវត្តន៍តាមច្បាប់វិន័យ ទៅដល់ក្រុមអ្នកដឹកនាំនិស្សិត និងសមាជិកចូលរួមទាំងឡាយ អំពីអំពើសម្ផុតធ្វើបាប ហើយការអនុវត្តន៍ច្បាប់វិន័យដែលបានថ្លែងបញ្ជាក់ប្រាប់ច្បាស់លាស់នៅក្នុងសៀវភៅណែនាំសិស្ស ឬនៅក្នុងក្រដាសផ្សព្វផ្សាយផ្សេងៗ ដែលស្ថាប័នសិក្សាបានរៀបចំធ្វើឡើងសំរាប់ណែនាំសិស្សទាំងឡាយ ។ ក្រុមប្រឹក្សាភិបាល ហើយនិង, ក្នុងករណីយនៃសាលាវិទ្យាល័យ គឺក្រុមប្រឹក្សាសាលា, នឹងត្រូវប្រកាសចេញជាផ្លូវការនូវច្បាប់ ឬក្រឹត្យក្រមទាំងឡាយដែលគ្រប់គ្រងទៅលើមាតិកា ហើយនិងភាពញឹកញាប់នៃការធ្វើរបាយការណ៍នានា ហើយក៏ផ្ញើបញ្ជូនរបាយការណ៍នោះទៅដល់អគ្គមេធាវី ស្តីពីការធ្វេសប្រហែសនៃស្ថាប័នក្នុងការធ្វើរបាយការណ៍ ។ បានកែប្រែច្បាប់ដោយជំពូកទី* St.1985, *មាត្រាទី* c-536; *បានកែប្រែច្បាប់ដោយជំពូកទី* St.1987, *មាត្រាទី* c.665 ។

# វិធានការពារជាមុននៃការសម្លុតធ្វើបាប
**BULLYING PREVENTION**

# សាលា ម៉ីដល់សិុក អាខាឌឺម៉ី ឆាទើ ប្រចាំក្រុងឡូវែល
Lowell Middlesex Academy Charter School

# សៀវភៅណែនាំសិស្សបន្ថែម
Student Handbook Supplement

យោលតាមច្បាប់ទូទៅនៅរដ្ឋម៉ាស្សាឈូសែត M.G.L. c. 71, មាត្រា 370, សកម្មភាពអ្វីមួយក៏ដោយដែលទាក់ទងទៅនឹង "អំពើសម្លុតធ្វើបាបគេនៅក្នុងសាលារៀននានា", សាលា អុិលម៉ាក់ គឺមានការប្តេជ្ញាចិត្តដើម្បីលើកតំកើងនូវបរិយាកាសដែលមានសុវត្ថិភាពល្អ ដើម្បីញុាំងអោយសិស្សទាំងអស់អាចទទួលជោគជ័យនៅក្នុងការសិក្សានិងអ្វីៗដែលគេប៉ងប្រាថ្នាសំរាប់ខ្លួនគេ ដើម្បីអោយក្លាយទៅជាពលរដ្ឋដ៏មានជោគជ័យ ។ គ្រប់ប្រភេទនៃអំពើរដែលធ្វើអោយអត្តរាយដល់ និងបណ្តាលអោយមានចរិយារំខាន, ការសម្លុតធ្វើបាប, ការសម្លុតធ្វើបាបតាមកំព្យូទ័រ ឬតាមរយៈអ៊ុនធឺនិត (cyberbullying) ហើយនិងការសងសឹក គឺនឹងមិនអាចប្រព្រឹត្តបានឡើយនៅក្នុងបរិវេណសាលារៀន ។

## និយមន័យផ្សេងៗនៃការសម្លុតធ្វើបាប - សុវត្ថិភាព - ការសងសឹក ៖
## Definitions of Bullying - Cyber Safety - Retaliation:

"ការសម្លុតធ្វើបាប, ភាសាអង់គ្លេសហៅថា Bullying", គឺជាការប្រើម្តងហើយម្តងទៀតដោយសិស្សណាម្នាក់ ឬច្រើនគ្នាដោយការសរសេរ, មាត់ទទេ ឬដោយការសម្តែងតាមអេលិចត្រូនិក ឬចលនាផ្លូវកាយ ឬកាយវិការ ឬដោយការផ្សំគ្នាជាមួយនឹងសកម្មភាពអ្វីក៏ដោយ ដែលសំដៅទៅលើជនរងគ្រោះណាម្នាក់ ដែល៖ (i) បណ្តាលអោយមានអត្តរាយឬគ្រោះថ្នាក់ផ្នែករាងកាយឬផ្លូវចិត្ត ដល់ជនរងគ្រោះ ឬដល់ទ្រព្យសម្បត្តិនៃជនរងគ្រោះ; (ii) បណ្តាលឲ្យជនរងគ្រោះស្ថិតនៅក្នុងសភាពភ័យខ្លាចពីការអត្តរាយដល់ខ្លួនឯង ឬខូចខាតដល់ទ្រព្យសម្បត្តិរបស់ខ្លួន; (iii) បង្កើតអោយមានបរិវេណក្លាយជាសត្រូវនៅសាលារៀនសំរាប់រងគ្រោះ; (iv) រំលោភលើសិទ្ធិទាំងឡាយនៃជនរងគ្រោះនៅសាលារៀន; ឬ (v) រំខានឬបង្អាក់ដល់ដំណើរការសិក្សាឬការប្រតិបត្តិការនៃសាលារៀន ។ សំរាប់គោលបំណងផ្សេងៗនៃជំពូកនេះ អត្ថន័យនៃការសម្លុតធ្វើបាប គឺរួមបញ្ចូលទាំងអំពើធ្វើបាបផ្សេងៗនៅតាមរយៈកំព្យូទ័រឬអ៊ុនធឺនិត ផងដែរ ។

"**អំពើធ្វើបាបតាមរយៈកំព្យូទ័រ** ឬអ៊ុនធឺនិត, ភាសាអង់គ្លេសហៅថា Cyber-bullying", គឺជាការសម្លុតធ្វើបាបដែលប្រើតាមរយៈគ្រឿងបច្ចេកទេស ឬការទាក់ទងគ្នាតាមរយៈអេឡិចត្រូនិច ដែលមានរួមបញ្ចូលទាំង, ប៉ុន្តែមិនគ្រាន់តែសំដៅទៅលើតែការផ្លាស់ប្តូរគ្នានៃនិមិត្តសញ្ញា, សញ្ញាដៃ, ការសរសេរ, រូប, សម្លេង, ទិន្នន័យ ឬបញ្ញានៃប្រភេទផ្សេងៗដែលបញ្ជូន, ផ្ញើ ឬចម្លងទាំងស្រុង ឬជាផ្នែកៗ តាមរយៈខ្សែលួស, វិទ្យុ, អេឡិចត្រូម៉ាញ៉េទិច, រូបភាពអេឡិចត្រូនិច ឬប្រព័ន្ធទស្សនសម្ព័ន្ធរូបភាព ដែលមានរួមទាំង, ប៉ុន្តែមិនកំណត់តែតាមរយៈប្រៃសណីយ៍អេឡិចត្រូនិច, ការទាក់ទងតាមអ៊ុនធឺនិត, ការផ្ញើសារបន្ទាន់ ឬការទាក់ទងតាមវត្ថុចម្លងតាមទាំងឡាយក៏ដោយ ។ អំពើសម្លុតធ្វើបាបតាមរយៈកំព្យូទ័រ ឬអ៊ុនធឺនិត គឺរួមបញ្ចូលផងដែរទាំង (i) ការបង្កើតបណ្តាញគេហទំព័រ ឬប្លក (blog) គឺការសរសេរតាមអុិធឺនិតដែលអ្នកបង្កើតនោះយកអត្តសញ្ញាណនៃអ្នកដទៃ ឬ (ii) ក្លែងខ្លួនជាជនណាម្នាក់ដែលជាអ្នកនិពន្ធដែលបានផ្សព្វផ្សាយមាតិកា ឬសារផ្សេងៗ, បើសិនជាការបង្កើតនោះ ឬការក្លែងបន្លំខ្លួននោះបង្កើតនូវស្ថានភាព ឬលក្ខខ័ណ្ឌណាមួយដែលរាយតាមលំដាប់នៅក្នុងខពិន័យផ្សេងៗទាំងស្រុង គឺពីលេខ (i) ដល់ (v) នូវអត្ថន័យនៃការសម្លុតធ្វើបាបនោះ ។ អំពើធ្វើបាបតាមរយៈកំព្យូទ័រ ឬអ៊ុនធឺនិតក៏មានរួមបញ្ចូលផងដែរតាមការចែកតាមរយៈមធ្យោបាយអេឡិចត្រូនិចនៃការទាក់ទងគ្នាទៅកាន់ជនច្រើនជាងមនុស្សម្នាក់ ឬការផ្សព្វផ្សាយនៃសម្ភារៈតាមរយៈឧបករណ៍អេឡិចត្រូនិចដែលមានមនុស្សម្នាក់ ឬច្រើននាក់អាចបើកមើលបាន, បើសិនជាការចែកចាយ ឬការផ្សព្វផ្សាយនោះ បង្កើតនូវស្ថានការ ឬលក្ខខ័ណ្ឌផ្សេងៗដែលបានរាយរាប់ជាលំដាប់នៅក្នុងអនុប្រយោគទាំងឡាយដូចបានអធិប្បាយនៅចំណុចលេខទី (i) ដល់

(v) ពីនិយមន័យនៃការសម្លុតធ្វើបាបនោះ ។

ការសងសឹកនឹងអ្នកណាម្នាក់ដែលបានរាយការពីអំពើសម្លុតធ្វើបាប, ដែលបានផ្តល់ពត៌មានក្នុងខៈណៈដែលមានការស៊ើបអង្កេតពីអំពើសម្លុតធ្វើបាប, ឬអ្នកសាក្សីទាំងឡាយ ឬមានពត៌មានដែលគួរឲ្យប្រើការបានអំពីអំពើសម្លុតធ្វើបាប នឹងត្រូវបានគេហាមឃាត់ជាដាច់ខាត ។

"**ជនរងគ្រោះ**, ភាសាអង់គ្លេសហៅថា Victim", ជាសិស្សណាម្នាក់ដែលប្រឆាំងនឹងអ្នកប្រព្រឹត្តនូវអំពើសម្លុតធ្វើបាប ឬការសងសឹកដែលបានប្រព្រឹត្តមកលើខ្លួន ។

បរិដ្ឋានដែលក្លាយជាសត្រូវ ឬភាសាអង់គ្លេសហៅថា Hostile environment គឺជាស្ថានការមួយដែលកើតឡើងដោយអំពើសម្លុតធ្វើបាបដែលបណ្តាលឲ្យបរិវេណសាលារៀនបានជ្រាបចូលជាមួយនឹងការធ្វើអោយភ័យខ្លាច (intimidation), ការចំអកឲ្យ (ridicule) ឬការប្រមាថ (insult) ដែលមានការធ្ងន់ធ្ងរបំផុត ឬដែលមានភាពពាតត្បាតដល់ការកែប្រែនូវស្ថានការផ្សេងៗនៃការសិក្សារបស់សិស្ស ។

<u>**ការហាមឃាត់ប្រឆាំងនឹងអំពើសម្លុតធ្វើបាប**</u> (<u>Prohibition Against Bullying</u>) (សូមពិនិត្យមើលវគ្គនៃច្បាប់ប្រតិបត្តិប្រចាំរដ្ឋម៉ាស្សាឈូសែត ជំពូកទី M.G.L. c. 71 មាត្រាតទី 370, សកម្មភាពណាមួយដែលទាក់ទងទៅនឹងអំពើសម្លុតធ្វើបាបនៅក្នុងសាលារៀន)

### អំពើសម្លុតធ្វើបាប គឺត្រូវបានគេហាមឃាត់ ៖

- នៅលើបរិវេណទាំងឡាយនៃសាលារៀន អ៊ិលម៉ាក់ ហើយនិងមហាវិទ្យាល័យ ម៉ីដល់ស៊ិក,
- នៅលើទ្រព្យសម្បត្តិដែលជាប់គ្នានឹងបរិវេណសាលារៀន, រួមបញ្ចូលទាំងឧទ្យានដែលនៅទល់មុខផ្លូវសាលារៀនផងដែរ,
- នៅឯសកម្មភាពដែលរៀបចំឡើងដោយសាលារៀន, ពិធីបុណ្យទាន, ឬកម្មវិធី ទោះបីវាស្ថិតនៅលើកន្លែង ឬក្រៅបរិវេណសាលារៀន,
- នៅលើរថយន្តរបស់សាលា ឬរថយន្តដទៃទៀតដែលជាកម្មសិទ្ធិរបស់សាលា, ជួលដោយសាលា ឬក៏បានប្រើប្រាស់ដោយក្រសួងសិក្សា ឬដោយសាលារៀនក៏ដោយ,
- តាមការប្រើប្រាស់នៃគ្រឿងបញ្ចេកទេស ឬឧបករណ៍អេឡិចត្រូនិចដែលជាកម្មសិទ្ធិរបស់សាលា, ជួលដោយសាលា ឬប្រើប្រាស់ជាប្រក្រតីដោយសាលារៀន, ឧទាហរណ៍ដូចជា នៅលើកំព្យូទ័ររបស់សាលា ឬនៅលើអ៊ិនធឺនិតដែលប្រើប្រាស់ដោយសាលារៀន,
- នៅឯកម្មវិធី ឬកន្លែងណាដែលមិនពាក់ពាន់នឹងសាលារៀន, ឬតាមការប្រើប្រាស់គ្រឿងបញ្ចេកទេសផ្ទាល់ខ្លួន ឬឧបករណ៍អេឡិចត្រូនិចផ្សេងៗ បើសិនជាការប្រព្រឹត្តអំពើសម្លុតធ្វើបាបនោះ បង្កើតនូវបរិវេណដែលបណ្តាលជាសត្រូវនៅឯសាលារៀនសំរាប់ជនរងគ្រោះ, ការរំលោភលើសិទ្ធិទាំងឡាយរបស់ជនរងគ្រោះនៅសាលារៀន, ឬអាក់ខានដល់ដំណើរការសិក្សាដ៏ច្រើនលើសលប់ ឬក៏ការប្រតិបត្តិការទូទៅ របស់សាលារៀន ។

## <u>ការរាយការណ៍ពីអំពើសម្លុតធ្វើបាប</u>

សាលារៀន អ៊ិលម៉ាក់ សង្ឃឹមថាសិស្ស, មាតាបិតា, អ្នកអាណាព្យាបាល ហើយនិងអ្នកដទៃៗទៀត ដែលបានប្រទះឃើញ ឬបានដឹងឮពីការកើតឡើងនៃអំពើសម្លុតធ្វើបាប ឬការសងសឹកអ្វីមួយដែលជាប់ទាក់ទងនឹងសិស្ស គឺត្រូវរាយការណ៍ទៅអោយសមាជិកណាម្នាក់នៃអភិបាលសាលារៀនភ្លាមៗ ។ របាយការណ៍អាចធ្វើឡើងជាលាយលក្ខអក្សរ ឬដោយមាត់ទទេទៅកាន់ចាងហ្វាងសាលា, ឬចាងហ្វាងរង ឬបុគ្គលិកណាម្នាក់ក៏បានដែរ ។ សមាជិកនៃបុគ្គលិកសាលារៀននោះ គឺត្រូវធ្វើរបាយការណ៍ជាប្រញាប់ទៅកាន់ចាងហ្វាងសាលា ឬចាងហ្វាងរងនូវការកើតមានឡើងនៃអំពើសម្លុតធ្វើបាបនោះ ឬការសងសឹកអ្វីដែលបុគ្គលិកសាលានោះបានប្រទះមើលឃើញ ឬបានដឹងឮ (ចូរមើលវគ្គនៃច្បាប់ប្រតិបត្តិប្រចាំរដ្ឋម៉ាស្សាឈូសែត ជំពូកទី M.G.L. c. 71 មាត្រាតទី 370, សកម្មភាពណាមួយដែលទាក់ទងទៅនឹងអំពើសម្លុតធ្វើបាបនៅក្នុងសាលា) ។របាយការណ៍ពីបទគ្រោះថ្នាក់ណាមួយ នឹងត្រូវបំពេញឡើងដោយសមាជិកបុគ្គលិកសាលាជាមួយនឹងសិស្សណាម្នាក់ ។ របាយការណ៍អាចជាអនាមិក, ប៉ុន្តែនឹងមិនមានសកម្មភាពពិន័យអ្វីមួយទៅដល់ឧក្រិដ្ឋជនឡើយ ដោយគ្រាន់តែសំអាងលើរបាយការណ៍អនាមិកនោះ ។ សមាជិកបុគ្គលិក, រួមទាំង, ប៉ុន្តែមិនកំណត់តែគ្រូបង្រៀន, អ្នកគ្រប់គ្រង, គិលានុបដ្ឋាយិកាប្រចាំសាលា, អ្នកថែរក្សាអាគារ, អគិរក្សសាលា, អ្នកធ្វើការជួយសង្គម, អ្នកឲ្យឱវាទដល់កម្មវិធីបង្រៀន ឬអ្នកជំនួយខាងផ្នែកសិក្សាទាំងឡាយ ។ សិស្សទាំងអស់នឹងត្រូវបានគេផ្តល់អោយនូវមធ្យោបាលដែលមានភាពប្រាកដនិយម, សុវត្ថិភាព, ឯកជន ហើយនិងសមរម្យទៅតាមអាយុសិស្ស ដើម្បីរាយការណ៍ និងពិភាក្សាពីឧបត្តិហេតុនៃអំពើសម្លុតធ្វើបាបជា

មួយសមាជិកបុគ្គលិក ឬជាមួយចាងហ្វាង ឬចាងហ្វាងរងសាលារៀន ។

នៅពេលដែលចាងហ្វាង ឬចាងហ្វាងរងបានទទួលរបាយការណ៍នោះហើយ គាត់ត្រូវចាប់ផ្តើមធ្វើការស៊ើបអង្កេតភ្លាមៗ ។ បើសិនជាចាងហ្វាង ឬចាងហ្វាងរង សំរេចថាអំពើសម្លុតធ្វើបាប ឬការសងសឹកនោះបានកើតឡើងមែននោះ គាត់នឹងត្រូវ ៖

- ប្រាប់ជាដំណឹងដល់មាតាបិតានៃជនរងគ្រោះ ហើយនិងគឺត្រូវគោរពតាមច្បាប់រដ្ឋ និងច្បាប់រដ្ឋាភិបាលសហព័ន្ធ, ត្រូវប្រាប់ពួកគេពីសកម្មភាពដែលបានអនុវត្តន៍ ដើម្បីការពារជាមុនកុំអោយចលនាអ្វីផ្សេងទៀតដែលទាក់ទងនឹងអំពើសម្លុតធ្វើបាប ឬការសងសឹកកើតមានឡើងទៀតឡើយ;
- ប្រាប់ជាដំណឹងដល់មាតាបិតានៃជនប្រព្រឹត្តអំពើល្មើសនោះផងដែរ;
- ដាក់ពិន័យអ្វីមួយដែលសមរម្យទៅតាមទោសកំហុស;
- ប្រាប់ដំណឹងដល់ក្រសួងនគរបាលក្រុងឡូវែល បើសិនជាចាងហ្វាង ឬចាងហ្វាងរងមានជំនឿជឿថាបទចោទប្រកាន់ឧក្រិដ្ឋកម្មនោះនឹងត្រូវការប្តឹងប្តល់ប្រឆាំងនឹងជនប្រព្រឹត្តឧក្រិដ្ឋកម្មនោះ;
- សកម្មភាពទាំងអស់នឹងត្រូវចងក្រងទុក ហើយនិងចុះបញ្ចូលទៅក្នុងបញ្ជីសិក្សាទាំងឡាយរបស់សិស្សផងដែរ ។

ការទាក់ទងនិងការផ្តល់ដំណឹងទាំងអស់នឹងត្រូវធ្វើឡើងសមស្របទៅតាមច្បាប់រដ្ឋនិងច្បាប់ឯកជនរបស់រដ្ឋាភិបាលសហព័ន្ធ និងបទបញ្ជាទាំងឡាយ ហើយនិងត្រូវសមស្របទៅតាមបទបញ្ជាទាំងឡាយរបស់រដ្ឋដែលចែងឡើងនៅក្នុងវគ្គ 603 CMR 49.00 ។

## <u>ប្រភពជំនួយផ្សេងៗសំរាប់សិស្ស</u>

សាលារៀន អ៊ិលម៉ាក់ នឹងផ្តល់ពត៌មានដែលមានការផ្លាស់ប្តូរជាទូទៅចំពោះការប្រឆាំងនឹងអំពើសម្លុតធ្វើបាបដែលនឹងបង្ហាញនៅក្នុងអង្គប្រជុំសិស្សធំៗ ហើយនិងត្រូវអនុវត្តន៍បន្ថែមទៀតនៅតាមថ្នាក់រៀនទាំងឡាយ ដូចជាការអោយឱវាទ ការប្រើប្រាស់នៃគ្រឿងផ្សាយពត៌មានផ្សេងៗ ។ យុទ្ធនាការបង្រៀនអប់រំនឹងស្ថាបនានូវបទជំនាញដល់អ្នកនៅក្បែរ ឬអ្នកជិតខាងទាំងឡាយ សំរាប់ឆ្លើយតបទៅនឹងអំពើសម្លុតធ្វើបាបនោះ ។

# សេរីភាពនៃការបញ្ចេញមតិយោបល់

## FREEDOM OF EXPRESSION

*យោងតាមច្បាប់រដ្ឋធម្មនុញ្ញនៃសហរដ្ឋអាមេរិក ហើយនិងច្បាប់ទូទៅនៃរដ្ឋម៉ាស្សាឈូសែត* M.G.L. *មាត្រាទី* C.71 Ss. 82-85, *សិទ្ធិផ្សេងៗរបស់សិស្សទាំងអស់ដែលចុះឈ្មោះចូលរៀននៅសាលា* ម៉ីដល់ស៊ិក អាខាឌីមី ឆាទើ ប្រចាំក្រុងឡូវែល *ទាក់ទងទៅនឹងសេរីភាពក្នុងការបញ្ចេញយោបល់ នឹងមិនត្រូវបំព្រួញអោយខ្វី, ដរាបណាតែសិទ្ធិនោះនឹងមិនបណ្តាលអោយមានការរំខាន ឬចលាចលនៅក្នុងសាលារៀន ។ សេរីភាពក្នុងការបញ្ចេញយោបល់នោះនឹងត្រូវរួមបញ្ចូលមិនត្រឹមតែការគំនិតអ្វីមួយឡើយ, សិទ្ធិផ្សេងៗនៃសិស្សទាំងឡាយ, រួមជាសមូហភាព ឬជាឯកជន គឺថា ៖ ក) ដើម្បីបញ្ចេញយោបល់ផ្ទាល់ខ្លួនដោយការនិយាយ និងសញ្ញាផ្សេងៗ, ខ) ដើម្បីសរសេរ, បោះពុម្ព និងចែកចាយគំនិតយោបល់របស់គេ, ហើយនិង គ) ដើម្បីរៀបចំអង្គប្រជុំដោយសុវត្ថិភាពនៅលើបរិវេណសាលា សំរាប់គោលបំណងនៃការបញ្ចេញមតិយោបល់ទាំងឡាយរបស់ខ្លួន ។*

**ការជុំគ្នា ឬការប្រជុំនានា ៖** *សាលា ម៉ីដល់ស៊ិក អាខាឌីមី ឆាទើ ប្រចាំក្រុងឡូវែល ផ្តល់ជារៀងរាល់វេលានូវកម្មវិធីនៃការប្រជុំគ្នា ឬសន្និបាតផ្សេងៗសំរាប់សិស្សទាំងឡាយជាប្រចាំឆ្នាំ ។ សិស្សទាំងអស់, ទោះមានចំនួនប៉ុន្មានក៏ដោយ, អាចមានសិទ្ធិនឹងរៀប*

*ចំធ្វើសន្និបាត ឬការប្រជុំគ្នាដោយសន្តិភាពនៅគ្រប់ពេលវេលាទាំងអស់, គឺរួមទាំងការប្រជុំផ្លូវការ និងក្រៅផ្លូវការ, លើកលែងតែការប្រជុំនោះនឹងធ្វើអោយមានការរំខានជាខ្លាំងដល់ដំណើរការសិក្សា ឬសកម្មភាពទាំងឡាយរបស់សាលារៀន ឬក៏នឹងបណ្តាលអោយសិស្សមានកល់ល្បិចក្នុងការមិនមកចូលរៀនក្នុងថ្នាក់ដោយគ្មានការអនុញ្ញាត ។ ការប្រជុំនានាដែលបានគ្រោងរៀបចំធ្វើដោយសិស្សទាំងឡាយនៅក្នុងកាលបរិច្ឆេទនៃម៉ោងសិក្សានៅសាលារៀន នឹងត្រូវបានគេអោយប្រព្រឹត្តទៅបាននៅពេល និងនៅទីកន្លែងណាមួយដែលបានទទួលអនុញ្ញាតឡើងដោយនាយកសាលា ឬអ្នកជំនួសកិច្ចការរបស់គាត់តែប៉ុណ្ណោះ ។ គ្មានការបញ្ចេញយោបល់ឬការសម្តែងអ្វីដោយសិស្សក្នុងការប្រើសិទ្ធិរបស់ខ្លួនឯង ដែលនឹងត្រូវចាត់ទុកថា ជាបញ្ចេញមតិទាក់ទងនឹងច្បាប់ប្រតិបត្តិនៃសាលារៀនឡើយ ហើយគ្មានបុគ្គលិកសាលារៀនទាំងឡាយណានឹងត្រូវទទួលខុសត្រូវចំពោះបណ្តឹងរដ្ឋប្បវេណី ឬទង្វើឧក្រិដ្ឋកម្មសំរាប់ការបញ្ចេញយោបល់ឬទស្សនៈអ្វីដែលធ្វើឡើង ឬផ្សព្វផ្សាយឡើងដោយសិស្សទាំងឡាយនោះឡើយ ។*

**ក្តារបិទប្រកាសដំណឹងផ្សេងៗ ៖** *មានការផ្តល់កន្លែងគ្រប់គ្រាន់នៅនឹងក្តារបិទប្រកាសដំណឹង សំរាប់អោយសិស្សនិងសមាគមនិស្សិតទាំងឡាយដើម្បីប្រើប្រាស់, រួមបញ្ចូលទាំងផ្ទៃគ្រប់គ្រាន់សំរាប់ដំណឹងប្រកាសផ្សេងៗដែលទាក់ទងទៅនឹងសកម្មភាពក្រៅកម្មវិធីសាលារៀន ឬពីកម្មវត្ថុចំណង់អ្វីផ្សេងៗដល់សិស្សទាំងឡាយ ។ ទោះបីជាគ្មានការចាប់ពិរុទ្ធ ឬការរិះគន់ ឬក៏តម្រូវការអោយសុំនូវការអនុញ្ញាតជាមុនស្តីពីមាតិកា ឬពាក្យពេជ្រនៃដំណឹង ឬការទាក់ទងផ្សេងៗទៀតក្តី ប៉ុន្តែលក្ខណៈភស្តុតាងវិនិច្ឆ័យទូទៅសំរាប់ការផ្សព្វផ្សាយដូចខាងក្រោមនេះ គឺត្រូវអនុវត្តន៍តាមជាកំហិត -*

*ក) ក្រដាសពត៌មានទាំងឡាយដែលបិទផ្សព្វផ្សាយត្រូវមានចុះនូវកាលបរិច្ឆេទដោយត្រឹមត្រូវដោយសិស្ស ឬក្រុមសិស្សដែលមានបំណងចង់បិទផ្សព្វផ្សាយដំណឹងទាំងនោះ ។ បើសិនការបិទក្រដាសផ្សព្វផ្សាយនោះ គឺជាដំណឹងប្រកាសនៃកម្មវិធីអ្វីមួយ គឺគប្បីត្រូវមានកាលបរិច្ឆេទនៃកម្មវិធីនោះ។ បើសិនជាការផ្សព្វផ្សាយនោះ ជាកំណត់ហេតុ ជាជាងជាការផ្សាយដំណឹងនៃកម្មវិធីអ្វីមួយវិញនោះ កាលបរិច្ឆេទនោះ គឺត្រូវតែជាថ្ងៃខែដែលបិទក្រដាសស្នាមប្រកាសនោះតែម្តង ។ ឈ្មោះនៃសិស្ស ឬក្រុមរបស់សិស្ស ក៏ត្រូវចុះភ្ជាប់ជាមួយនឹងក្រដាសស្នាមផ្សព្វព្យាយនោះផងដែរ ។*

*ខ) សិស្ស ឬក្រុមនិស្សិត នឹងត្រូវបានគេស្នើសុំអោយបកផ្ដាកប្រកាសចេញបន្ទាប់ពីបានបិទផ្សព្វផ្សាយអស់រយៈពេលដ៏សមរម្យរួចហើយនោះ ដើម្បីអោយអ្នកដទៃអាចប្រើប្រាស់ក្តារបិតប្រកាសដំណឹងនោះផងដែរ ។*

*គ) សាលារៀននឹងមិនអនុញ្ញាតឲ្យបិទក្រដាសផ្សព្វផ្សាយដំណឹងអ្វី ដែលបណ្តាល ឬជួយផ្តល់អោយមានការអាក់ខានដល់ដំណើរការសិក្សា, គឺអ្វីៗក៏ដោយ ដែលអាចរំខាន ឬញុំាងគ្រូៗអោយវៀរចាកពីការបង្រៀន ឬសិស្សទាំងឡាយពីការសិក្សា ។*

*ឃ) ក្រដាស ឬដំណឹងផ្សព្វព្យាយផ្សេងៗនៃកម្មវិធី ឬព្រឹត្តិការណ៍ទាំងឡាយដែលត្រូវបិទនៅលើក្តារបិទប្រកាស (ដូចជាបិទនៅលើជញ្ជាំង, ទ្វារ ឬបង្អួចទាំងឡាយ) ដោយគ្មានការអនុញ្ញាតពីនាយកសាលារៀន នឹងត្រូវបានគេបកចេញ ដើម្បីការថែរក្សាសណ្តាប់ធ្នាប់ទាក់ទងនឹងច្បាប់ការពារអគ្គីភ័យនិងសុវត្ថិភាពផ្សេងៗ ។*

**ការចែកចាយនៃក្រដាសបោះពុម្ពផ្សាយ និងការផ្សព្វផ្សាយញត្តិទាមទារសិទ្ធិផ្សេងៗ ៖** *សិស្សទាំងឡាយនឹងមានសេរីភាពក្នុងការចែកចាយប័ណ្ណប្រកាស* (handbill), *សន្លឹកប័ណ្ណ* (leaflet) *ហើយនិងក្រដាសចម្លងផ្សេងៗ ហើយនិងការប្រមូលហត្ថលេខា*

*នៅលើញត្តិនានា ដែលទាក់ទងទៅនឹងសកម្មភាពទាំងឡាយដែលនៅក្នុងសាលា ឬក្រៅសាលារៀន ឬកម្មវត្ថុអ្វីផ្សេងៗទៀត ដែលទាក់ទងនឹងចំណាប់អារម្មណ៍ដល់សិស្សទូទៅ ។ ទោះបីជាគ្មានការចាប់ពិរុទ្ធ ឬការរិះគន់អ្វីជាមុន ឬការសុំអនុញ្ញាតអ្វីជាមុនទៅលើមាតិការឿង ឬចំពោះពាក្យពេជទាំងឡាយនោះក៏ដោយ ប៉ុន្តែលក្ខណៈកស្តុតាមវិនិច្ឆ័យទូទៅដូចខាងក្រោមនេះ គឺនឹងត្រូវអនុវត្តន៍ឡើង ជាចាំបាច់ -*

*ក) គ្រប់ក្រដាសស្នាមផ្តិតផ្សព្វផ្សាយ ហើយនិងញត្តិទាំងអស់ដែលបានចែកចាយ ឬផ្ញើបង្ហិលទៅមកនៅលើបរិវេណសាលា គឺត្រូវមានភ្ជាប់ឈ្មោះនៃសមាគមដែលជួយឧបត្ថម្ភគាំទ្រ ។*

*ខ) ការចែកចាយនៃក្រដាសផ្សព្វផ្សាយដំណឹង ឬការប្រមូលហត្ថលេខាទាំងឡាយ នឹងត្រូវមានកំរិតពេលវេលានៅមុនពេលសាលារៀនចាប់ផ្តើម, បន្ទាប់ពីចេញពីសាលារៀន និងនៅក្នុងម៉ោងញុំាអាហារ ដើម្បីធ្វើយ៉ាងណាកុំអោយប៉ះពាល់ដល់កម្មវិធីសិក្សានៃសាលារៀន ។*

*គ) កន្លែងនិងលក្ខណៈនៃសកម្មភាពទាំងឡាយនោះ គឺត្រូវមានកំហិតត្រឹមត្រូវដែលអនុញ្ញាតឡើងតាមការប្រតិបត្តិជាប្រក្រតីនៃសាលារៀន ដើម្បីបន្តដំណើរការដោយគ្មានការអាក់ខានអ្វីមួយ ហើយនិងដើម្បីការពារកុំអោយមានប្រើប្រាស់នៃការបង្ខិតបង្ខំ ឬការដាក់កំហិតអ្វីមួយក្នុងការប្រមូលយកនូវការចុះហត្ថលេខានៅលើញត្តិផ្សេងៗនោះផងដែរ ។*

*ឃ) ក្នុងករណីដែលញត្តិទាំងឡាយដែលបានផ្តល់ឡើងដោយសិស្សទៅដល់នាយកសាលារៀន គឺសិស្សនឹងមានសិទ្ធិគ្រប់គ្រាន់ដើម្បីយកទៅពិចារណា ហើយនិងត្រូវទទួលចម្លើយមកវិញផងដែរ ។*

*ង) ការចែកចាយ ហើយនិងការលក់ដូរនៃសម្ភារៈសំរាប់លុយកាក់ដោយបុគ្គលណាម្នាក់ ឬអង្គការណាមួយ គឺនឹងត្រូវបានគេហាមឃាត់មិនអោយប្រព្រឹត្តឡើយដោយសាលា ម៉ីដល់ស៊ិក អាខាឌីម៉ី ឆាទើ ប្រចាំក្រុងឡូវែល បានឡើយ ។*

## ច្បាប់ស្លៀកពាក់ខោអាវ

## DRESS CODE

1. **សំលៀកបំពាក់សាលារៀនត្រឹមត្រូវ ៖**

   *ក). ខោអាវខើចខ្ចីដែលបញ្ចេញសន្ទះខ័ណ្ឌទ្រូងឬក្បាលពោះនឹងមិនអនុញ្ញាតឲ្យស្លៀកពាក់ឡើយ ។ នេះមានន័យថា អាវនិងខោទាំងឡាយ គឺត្រូវបិទអោយជិត ដើម្បីកុំអោយចេញឃើញសាច់ ។*

   *ខ). ខោឬអាវទ្រនាប់ (ដូចបានបញ្ជាក់ដោយពាក្យថា សំពត់ទ្រនាប់, ភាសាអង់គ្លេសហៅថា* ***under**wear*) *នឹងមិនត្រូវបញ្ចេញអោយឃើញឡើយ ។ ខោអាវទាំងឡាយត្រូវគ្របអោយជិតខោអាវទ្រនាប់ទាំងអស់នោះ ។*

*គ). ខោខ្លី, សំពត់ខ្លី ហើយនិងអាវខើចខ្លីទាំងឡាយនឹងមិនត្រូវបានគេអនុញ្ញាតអោយស្លៀកពាក់នៅក្នុងសាលាឡើយ ។ សំពត់ និងខោខ្លីទាំងឡាយនឹងមិនត្រូវខ្លីជាងពាក់កណ្តាលភ្លៅឡើយ ។ ខោវែងប្រភេទមូដខ្លីដូចពួកអ្នកធ្វើការតាមនាវា ឬយន្តហោះ គឺអាចអនុញ្ញាតអោយស្លៀកពាក់បាន ។ ខោអាវមុជទឹកប្រភេទណាក៏ដោយ ក៏មិនអនុញ្ញាតអោយស្លៀកពាក់នៅក្នុងបរិវេណសាលារៀនឡើយ ។*

*ឃ). អាវស្រីម៉្យាងពាក់ពីលើខ្លួន* (Camisoles) *គឺត្រូវគ្រប់អោយជិតខោអាវទាំងឡាយ ។ (ជាទូទៅ គឺត្រូវពាក់បិទអោយជិតដងស្មាទាំងសងខាង និងដើមទ្រូងផងដែរ )។*

2. **អាវយឺតនិងគ្រឿងអលង្ការត្រឹមត្រូវ ៖** *មិនអនុញ្ញាតមានសញ្ញាថ្នាំ, សុរា ឬរូបភាពនៃសាស្ត្រាវុធផ្សេងៗ ឬរូបទាំងឡាយណាដែលមិនសមស្របទៅនឹងតម្លៃដ៏ត្រឹមត្រូវតាមសិលធម៌ទាំងឡាយនៃសាលារៀន អ៊ុលម៉ាក់ នោះឡើយ ។ ឧទាហរណ៍ដូចជា អាវដែលមានគូរូបភាព ដើម្បីបំភ័យ ឬគំរាមកំហែងគេ (ឧទាហរណ៍ "គ្មានការចៃចូវ ឬញុះញង់" ឬ អង់គ្លេសហៅថា* "no snitching") *គឺវាមិនសមស្របទៅតាមតម្លៃអកិសមាចារ (សីលធម៌) របស់យើងឡើយ ។*

3. **សំរាប់ឳកាសខ្លះៗ សិស្សនឹងត្រូវបានគេស្នើអោយស្លៀកសំលៀបំពាក់ត្រឹមត្រូវតាមរបៀបអ្នកធ្វើការពាណិជ្ជកម្មផ្សេងៗ**
   *ក). អាវដែលមានទ្រនាប់* (Collared shirt), *ខោពណ៌កាគីសំរាប់ប្រុស*
   *ខ). សំពត់ហ្សីបនិងអាវត្រឹមចង្កេះ ឬអាវដីណូ ហើយនិងអាវ ឬសំលៀកបំពាក់សំរាប់ស្ត្រីធ្វើការទាំងឡាយ ។*

# គ្រឿងបច្ចេកទេស

## TECHNOLOGY

*កំព្យូទ័រទាំងឡាយដែលនៅក្នុងសាលារៀន ម៉ិដល់ស៊ិក អាខាឌីមី ឆាទើ ប្រចាំក្រុងឡូវែល គឺសំរាប់ប្រើប្រាស់ចំពោះតែគោលបំណងសិក្សាតែប៉ុណ្ណោះ ។ ការប្រើប្រាស់មិនត្រឹមត្រូវនៃម៉ាស៊ីនកំព្យូទ័រ ឬការប្រើប្រាស់នៃការគំរាមកំហែង ឬភាសាណាដែលប្រមាថមើលងាយតាមរយៈអ៊ីម៉ែល, អ៊ិនធឺនិត ឬកម្មវិធីកំព្យូទ័រដទៃផ្សេងទៀតក្តី គឺនឹងត្រូវបាត់បង់នូវសិទ្ធិសេរីភាពក្នុងការប្រើប្រាស់កំព្យូទ័រ ហើងក៏នឹងត្រូវទទួលការព្រមានពិន័យថែមទៀតផងដែរ ។ អាកប្បកិរិយាដែលត្រូវបានគេហាមឃាត់ដទៃទៀតគឺមានរួមបញ្ចូលទាំង ៖ ការចម្លងតាមកំព្យូទ័រនូវបទភ្លេង, រូបវិឌីអូ, ឬល្បែងវិឌីអូទាំងឡាយ; ការប្រើប្រាស់នូវកន្លែងគេហទំព័រដដែកទាក់ទងគ្នាផ្សេងៗ ឬបណ្តាញគេហទំព័រទាក់ទងគ្នាផ្សេងៗទៀត; ហើយនិងការចូលមើល ឬការចម្លងរូបភាពអាសគ្រាមផ្សេងៗ ។ សិស្សទាំងឡាយក៏មិនអាចនាំចូលមកនូវភេសជ្ជៈ ឬម្ហូបអាហារចូលក្នុងបន្ទប់កំព្យូទ័របានដែរ ។ សិស្សទាំងឡាយណាដែលមិនប្រព្រឹត្តតាមច្បាប់បញ្ញតិនេះ គឺនឹងត្រូវទទួលការព្រមានពិន័យជាពុំខានឡើយ ។*

## សព្ទចោរកម្ម
## PLAGIARISM

*សាលារៀន អ៊ិលម៉ាក់ នឹងមិនលួចស័ព្ទ ឬយកសម្បត្តិនិពន្ធអ្នកដទៃឡើយ ។ ស័ព្ទចោរកម្ម គឺជាការលួចយកនិពន្ធអ្នកឯទៀត ឬយកគំនិតទាំងឡាយរបស់អ្នកដទៃទៀតដោយគ្មានការអនុញ្ញាត ហើយចាត់ទុកថាជាគំនិតរបស់ខ្លួនឯង ។ ប្រភេទច្រើនជាញឹកញាប់ដែលទាក់ទងនឹងស័ព្ទចោរកម្មនេះ គឺមានដូចតទៅ ៖*

**ការផ្លាស់ប្តូរកែប្រែអត្ថបទ (Context Change)** ៖ *បន្ទំនូវការចម្លងដោយការផ្លាស់ប្តូរនូវអត្ថបទនៃក្រដាសនិពន្ធដើម ។*

**ការបំបាត់កំណត់ហេតុនៅក្រោមទំព័រសៀវភៅ (Missing Footnotes)** ៖ *រំលងកំណត់ហេតុទាំងឡាយទាំងស្រុងតែម្តង ។*

**ឯកសារយោងក្លែងក្លាយ (False References)** ៖ *ការដកស្រង់យកឯកសារពីសៀវភៅទាំងឡាយដែលគ្មានការពុម្ព, ឬអត្ថបទស្រាវជ្រាវផ្សេងៗ ឬការអោយតម្លៃទៅប្រភពនៃឯកសារនានាដែលគ្មានការទាក់ទងទៅនឹងប្រធានបទ ។*

*សិស្សណាម្នាក់ដែលត្រូវបានគេចាប់បានលួចយកទ្រព្យនិពន្ធអ្នកដទៃ នឹងត្រូវបានបុគ្គលិកសាលាព្រមានជាលើកដំបូង ។ ការប្រព្រឹត្តអំពើនេះបន្តទៀត សិស្សនឹងត្រូវដាក់អោយជួបទៅនឹងគណៈកម្មការពិនិត្យវិនិច្ឆ័យអភិសមាចារ (តម្លៃសីលធម៌)។*

## ច្បាប់ប្រើប្រាស់ទូរស័ព្ទដៃ
## CELL PHONE POLICY

*ពីព្រោះដោយមានការរំខានជាច្រើន ដែលកើតមានឡើងដោយសារទូរស័ព្ទផ្សេងៗ, សាលារៀន អ៊ិលម៉ាក់បានចេញជាច្បាប់ប្រតិបត្តិដូចខាងក្រោមនេះ ៖*

- *លើកទីមួយដែលបុគ្គលិកឃើញ ឬស្តាប់ឮទូរស័ព្ទណាមួយ គឺទូរស័ព្ទនោះនឹងត្រូវដកហូតយកទៅអោយចាងហ្វាង ឬចាងហ្វាងរងសាលា ហើយសិស្សនឹងអាចទទួលយកវិញបាននៅពេលចប់ម៉ោងសិក្សា ។*
- *លើកទីពីរដែលបុគ្គលិកសាលាឃើញ ឬស្តាប់ឮទូរស័ព្ទ វានឹងត្រូវបានគេយកចេញ ហើយនិងអាចទទួលមកវិញដោយមាតាបិតាសិស្ស ។*
- *លើកទីបីដែលបុគ្គលិកឃើញ ឬស្តាប់ឮទូរស័ព្ទ សិស្សនឹងតម្រូវអោយទៅជួបប្រជុំជាមួយនឹងគណៈកម្មការពិនិត្យវិនិច្ឆ័យអភិសមាចារ ។*

*យើងបានយល់ហើយថា វាមានមូលហេតុល្អជាច្រើនយ៉ាង ដែលសិស្សណាម្នាក់ត្រូវមានទូរស័ព្ទជាកម្មសិទ្ធិរបស់ខ្លួន ។ ប៉ុន្តែ ទោះបីជាយ៉ាងណាក៏ដោយ, នៅពេលម៉ោងសិក្សានៅក្នុងសាលារៀន វាគឺត្រូវគេបានហាមឃាត់មិនអោយប្រើប្រាស់ឡើយ ។ បើមានភាពអាសន្នត្រូវការទាក់ទងសិស្ស គឺអាចទូរស័ព្ទមកកាន់សាលាដោយផ្ទាល់តាមទូរស័ព្ទលេខ* (978) 656-3165 ។

# ច្បាប់ទាក់ទងនឹងថ្ងៃបិទសាលារៀន

## SCHOOL CANCELLATION POLICY

*ក្នុងករណីកិច្ចដែលស្ថានភាពអាកាសធាតុនឹងបណ្តាលអោយសាលារៀន អ៊ិលម៉ាក់ បិទថ្នាក់រៀននានាសំរាប់ថ្ងៃណាមួយនោះ*, *ទូរសារដំណឹងនៅការិយាល័យធំនឹងត្រូវបានគេថតសម្លេងនៃការផ្លាស់ប្តូរកម្មវិធីសិក្សា ដែល បញ្ជាក់ពីការបិទថ្ងៃសិក្សារបស់សាលារៀនសំរាប់ថ្ងៃនោះ ។ លេខទូរស័ព្ទប្រចាំការិយាល័យសាលារៀន អ៊ិលម៉ាក់ គឺ* (978) 656-3165 ។

*ជាបន្ថែមពីនេះទៅទៀតនោះ គឺថាការផ្សាយដំណឹងពីការបិទសាលា នឹងមានផ្សព្វផ្សាយតាមរយៈដូចខាងក្រោមនេះ ៖*

**WCVB TV Channel 5**
**www.LMACS.org**

*បើសិនជាលោកអ្នកមិនបានស្តាប់ឮ ឬមើលឃើញសាលា ម៉ីដល់ស៊ិក អាខាឌឹមុី ឆាទើ ប្រចាំក្រុងឡូវែលបិទទ្វារសាលាទេនោះ*, *នោះមានន័យថា នឹងមានថ្នាក់រៀនជាធម្មតា ។ ការបិទ ឬការពន្យារពេលនៃសាលាសាធារណៈប្រចាំក្រុងឡូវែល នឹងមិនមានន័យថា សាលា អ៊ិលម៉ាក់ នឹងមានការបិទ ឬការពន្យារពេលនោះឡើយ ។*